ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ប្រព័ន្ធរំឭកជាមុនសម្រាប់ទប់ស្កាត់សិស្សបោះបង់ការសិក្សា



## គោលការណ៍ណែនាំសម្រាប់គណៈគ្រប់គ្រងសាលារៀន

រៀបចំដោយ
ក្រសួងអប់រំ យុវជន និងកីឡា
ឆ្នាំ ២០១៩

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ** ១៤៨៣ **អយក.មថម**

ថ្ងៃ សុក្រ ២រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០១៩

**ជម្រាបមក**

**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការប្រើប្រាស់ " គោលការណ៍ណែនាំប្រតិបត្តិសាលាកុមារមេត្រីសម្រាប់គណៈគ្រប់គ្រងតាមសាលារៀន " និង " គោលការណ៍ណែនាំប្រព័ន្ធរំពឹកជាមុនសម្រាប់ទប់ស្កាត់សិស្សបោះបង់ការសិក្សា " ។

តបតាមកម្មវត្ថុខាងលើ សូមលោកប្រធានជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការយូនីសេហ្វ (UNICEF) បានរៀបរៀងនិងចងក្រងឯកសារណែនាំសម្រាប់គណៈគ្រប់គ្រងសាលារៀនចំនួនពីរច្បាប់គឺ៖ "គោលការណ៍ណែនាំប្រតិបត្តិសាលាកុមារមេត្រីសម្រាប់គណៈគ្រប់គ្រងតាមសាលារៀន" និង "គោលការណ៍ណែនាំប្រព័ន្ធរំពឹកជាមុនសម្រាប់ទប់ស្កាត់សិស្សបោះបង់ការសិក្សា" ។ ឯកសារទាំងពីរនេះមានគោលដៅលើកកម្ពស់ការគ្រប់គ្រង ការថែរក្សាសិស្ស ការតាមដានសិស្សដែលប្រឈមនឹងការបោះបង់ការសិក្សា ការបង្កើនប្រសិទ្ធភាពនៃ ការបង្រៀន និងរៀនតាមរយៈការចែករំលែកបទពិសោធន៍គ្នារវាងគ្រឹះស្ថានសិក្សានានា និងការចូលរួមគាំទ្រក្នុងវិស័យអប់រំពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីអភិវឌ្ឍសាលារៀន និងកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្ស។

អាស្រ័យហេតុនេះ សូមលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវឯកសារទាំងពីរនេះដល់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា ព្រមទាំងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព ។

សូម លោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

ចម្លងជូន៖
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានអប់រំ
- នាយកដ្ឋានពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ.នាមចទ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

# អារម្ភកថា

ការអប់រំមូលដ្ឋានជាសិទ្ធិរបស់កុមារហើយសិទ្ធិនេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ក្នុងបរិការណ៍នេះ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតប្រព័ន្ធរម្លឹកជាមុនដើម្បីកំណត់អត្តសញ្ញាណសិស្ស ដែលងាយប្រឈមនឹងការបោះបង់ការសិក្សា និងចាត់វិធានការទប់ស្កាត់មិនឱ្យពួកគេបោះបង់ការសិក្សា ក៏ដូចជាធានាបាននូវសិទ្ធិរបស់កុមារ ក្នុងការទទួលបានយ៉ាងហោចណាស់ការអប់រំមូលដ្ឋាន។

ឯកសារ “**ប្រព័ន្ធរម្លឹកជាមុនសម្រាប់ទប់ស្កាត់សិស្សបោះបង់ការសិក្សា**” ជាឧបករណ៍សម្រាប់ឱ្យគណៈគ្រប់គ្រងសាលារៀនជួយលុបបំបាត់សិស្សបោះបង់ការសិក្សាតាមសាលារៀន។ ឯកសារនេះត្រូវបានរៀបរៀងឡើងដោយក្រុមការងារដែលមានសមាសភាពមន្ត្រីមកពីនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ នាយកដ្ឋានធានាគុណភាពអប់រំ និងមន្ទីរ ការិយាល័យ អប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធកម្រិតសាលារៀនមកពីខេត្តសៀមរាប រតនគីរី ស្ទឹងត្រែង តាកែវ ព្រះវិហារ ព្រះសីហនុ កំពត កំពង់ចាម និងកំពង់ស្ពឺ ដោយសហការជាមួយអង្គការ UNICEF។

គោលការណ៍ណែនាំនេះ ត្រូវបានរៀបរៀងឡើងឱ្យឆ្លើយតបនឹងអនុសាសន៍នៃការវាយតម្លៃសាលាកុមារមេត្រីឆ្នាំ ២០១៦ និងត្រូវបានរៀបចំឡើងដើម្បីធានាថា សាលាអប់រំ មូលដ្ឋានទាំងអស់ចូលរួមចំណែកធ្វើយ៉ាងណាឱ្យកម្ពុជា ឈានទៅរកការប្តេជ្ញាចិត្តអន្តរជាតិឆ្ពោះទៅសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ ដែលសំដៅធានាបាននូវការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ការអប់រំត្រូវបានចាត់ទុកជាសិទ្ធិមនុស្សជាសារវន្ត ហើយសាលារៀនគួរយកចិត្តទុកដាក់លើកុមារគ្រប់រូប។ ដូច្នេះ ការលុបបំបាត់ការបោះបង់ការសិក្សា ត្រូវបានចាត់ទុកជាអាទិភាពខ្ពស់សម្រាប់សាលាអប់រំមូលដ្ឋានទាំងអស់។

នាយកសាលា និងគណៈគ្រប់គ្រងសាលារៀនត្រូវសហការគ្នាយ៉ាងជិតស្និទ្ធិជាមួយ គ្រូបង្រៀន សហគមន៍ ព្រះសង្ឃ និងអ្នកដឹកនាំសាសនាផ្សេងទៀត ក្រុមប្រឹក្សាកុមារ និងប្រធានថ្នាក់ និងអាជ្ញាធរមូលដ្ឋាន ដើម្បីធានាការអនុវត្តប្រព័ន្ធរម្លឹកជាមុនប្រកបដោយប្រសិទ្ធភាព។

មានការរំពឹងទុកថា ការកំណត់អត្តសញ្ញាណសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា ត្រូវធ្វើឡើងមុនពេលចាប់ផ្តើមឆ្នាំសិក្សា និងត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ខែ។ ការកំណត់អត្តសញ្ញាណសិស្សទាំងនេះ និងតម្រូវការរបស់ពួកគេឱ្យបានឆាប់នឹងជួយឱ្យសាលាអាចផ្តួចផ្តើម និងគ្រោងថវិកាសម្រាប់សកម្មភាពនានាក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំ។ គួរកំណត់អាទិភាពសកម្មភាពសម្រាប់ទប់ស្កាត់សិស្សបោះបង់ការសិក្សា និងសម្រេចបានលទ្ធផលរៀនសូត្រល្អប្រសើរក្នុងដំណើរការអភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំ។ សកម្មភាពដែលបានអនុវត្តត្រូវត្រួតពិនិត្យឱ្យបានទៀងទាត់ដើម្បីវាយតម្លៃពីប្រសិទ្ធភាពរបស់ពួកគេ ជាពិសេសក្នុងអំឡុងកិច្ចប្រជុំប្រចាំខែ។ ប្រសិនបើ សកម្មភាពនោះមិនទទួលបាននូវលទ្ធផលដែលចង់បាន គណៈគ្រប់គ្រងតាមសាលារៀនគួរតែសួរខ្លួនឯងថា ហេតុអ្វី? ហើយក្នុងអំឡុងកិច្ចប្រជុំប្រចាំខែនឹងធ្វើការកែសម្រួលសកម្មភាព ដើម្បីធានាថាសិស្សមិនបោះបង់ការសិក្សា។

ឯកសារនេះរៀបរាប់ពីដំណើរការអនុវត្តន៍គោលនៃប្រព័ន្ធរម្លឹកជាមុន ប៉ុន្តែសាលារៀន អាចកែសម្រួលអន្តរាគមន៍ទៅតាមតថភាពក្នុងមូលដ្ឋានដើម្បីបំពេញតម្រូវការជាក់ស្តែង។ ឯកសារនេះផ្អែកតាមការអនុវត្តល្អបំផុតនៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យ និងដកស្រង់ចេញពីអង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋាន និងអន្តរជាតិ។ ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថាសាលានឹងមានការយកចិត្តទុកដាក់លើការអនុវត្តប្រព័ន្ធរម្លឹកជាមុននេះ ហើយសាលារៀនត្រូវចាប់ផ្តើមអនុវត្តភ្លាមៗ ដោយមិនត្រូវរង់ចាំសេចក្តីណែនាំបន្ថែមទៀតនោះទេ។

សូមអរគុណ

# មាតិកា


អារម្ភកថា 3

មាតិកា5 5

១. សេចក្តីផ្តើម 7

២. ខ្លឹមសារសង្ខេបស្តីពីប្រព័ន្ធរម្លឹកជាមុន 9

| ២.១ ការបង្កើតគណៈកម្មការប្រព័ន្ធរម្លឹកជាមុន 9

| ២.២ ការកំណត់អត្តសញ្ញាណសិស្ស ដែលងាយប្រឈមនឹងការបោះបង់ការសិក្សា 10

| ២.៣ រៀបចំអន្តរាគមន៍ដើម្បីជួយដល់សិស្សដែលប្រឈមក្នុងរយៈពេលវែង 11

| ២.៤ ការតាមដានសិស្ស និងអវត្តមានសិស្ស 11

| ២.៥ ការស្វែងយល់ពីសកម្មភាពឆ្លើយតបបឋម 14

| ២.៦ ការបង្កើនការយល់ដឹង និងការតស៊ូមតិក្នុងសហគមន៍ 14

| ២.៦.១ ច្បាប់សំខាន់ៗនៅកម្ពុជាដែលធានាសិទ្ធិ ទទួលបានការអប់រំរបស់កុមារ 15

| ២.៦.២ អត្ថប្រយោជន៍នៃការអប់រំ និងសារៈសំខាន់នៃការ ចុះឈ្មោះចូលរៀននៅអាយុត្រឹមត្រូវ 15

| ២.៦.៣ ការចូលរួមចំណែករបស់មាតាបិតា ដល់ការបញ្ចប់ការសិក្សារបស់កូន 16

៣. តួនាទីរបស់អ្នកពាក់ព័ន្ធ 18

| ៣.១ អ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន 18

| ៣.២ តួនាទីរបស់ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក ឬការិយាល័យ អប់រំ យុវជន និងកីឡា 25

| ៣.២.១ ផ្តោតអាទិភាពលើការបង្កើត និងការកសាងសមត្ថភាព ប្រព័ន្ធរម្លឹកជាមុនក្នុងពេលពិនិត្យតាមដាន 25

| ៣.២.២ គ្រប់គ្រងទិន្នន័យសិស្ស 25

| ៣.២.៣ ការវិភាគផែនការប្រតិបត្តិប្រចាំឆ្នាំ 25

| ៣.៣ តួនាទីរបស់មន្ទីរ អប់រំ យុវជន និងកីឡា 25

| ៣.៣.១ ការវិភាគទិន្នន័យស្តីពីការទប់ស្កាត់ការបោះបង់ការសិក្សា 25

| ៣.៣.២ ការវិភាគផែនការប្រតិបត្តិសាលារៀន 26

| ៣.៣.៣ ការកសាងសមត្ថភាព 26

| ៣.៣.៤ ផែនការថ្នាក់ខេត្តសម្រាប់ការឆ្លើយតបនឹងសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា 26

## ៤. អន្តរាគមន៍ទប់ស្កាត់សិស្សបោះបង់ការសិក្សា 27

| ៤.១ សកម្មភាពឆ្លើយតបបឋម 27

| ៤.២ អន្តរាគមន៍រយៈពេលវែងផ្សេងទៀតដើម្បីជួយទប់ស្កាត់សិស្សបោះបង់ការសិក្សា 31

## ៥. ឧបសម្ព័ន្ធ 43

| ៥.១ ទម្រង់បាយការណ៍ចុះតាមផ្ទះ 43

| ៥.២ តារាងកំណត់អត្តសញ្ញាណសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា 44

| ៥.៣ ទម្រង់គ្រប់គ្រងករណី 45

| ៥.៤ តារាងគ្រប់គ្រងឥរិយាបថ 46

| ៥.៥ លិខិតអញ្ជើញអវត្តមាន ១០ ថ្ងៃ 47

| ៥.៦ ទម្រង់កិច្ចសន្យាចូលរួម 48

| ៥.៧ ធនធានបន្ថែមសម្រាប់ជួយដល់ស្វ័យសិក្សា 49

| ៥.៨ ករណីសិក្សាស្តីពីសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា 50

| ៥.៨.១ សិស្សធុញទ្រាន់នឹងការរៀន ប៉ុន្តែឪពុកម្តាយជំរុញឱ្យរៀន 50

| ៥.៨.២ មូលហេតុដែលសិស្សរៀនពូកែហើយបោះបង់ការសិក្សា 51

| ៥.៨.៣ សិស្សរៀនពូកែឪពុកម្តាយមានលទ្ធភាពតែមិត្តភក្តិអូសទាញឱ្យចំណាកស្រុក 52

| ៥.៨.៤ សិស្សគេចសាលាមិនចូលរៀនទៅលេងល្បែងនៅជុំវិញសាលា 54

# ១ សេចក្តីផ្តើម

ប្រព័ន្ធរម្លឹកជាមុនសម្រាប់ទប់ស្កាត់សិស្សបោះបង់ការសិក្សា គឺជាសកម្មភាពគន្លឹះក្នុងការសម្រេចបានលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌ និងសិទ្ធិទទួលបានការអប់រំរបស់កុមារគ្រប់រូបដែលត្រូវបានធានាក្នុងរដ្ឋធម្មនុញ្ញកម្ពុជា។ ប្រព័ន្ធនេះផ្តោតសំខាន់លើសមាសភាគទី១ នៃគោលនយោបាយសាលាកុមារមេត្រីដែលធានានូវលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌។ សាលាកុមារមេត្រីគឺជាអន្តរាគមន៍ស្នូលក្នុងចំណោមគោលនយោបាយអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ក្របខណ្ឌនេះត្រូវបានអនុវត្តសាកល្បងក្នុងខេត្តគោលដៅមួយចំនួនដោយដៃគូអភិវឌ្ឍន៍តាំងពីឆ្នាំ២០០២។ នៅឆ្នាំ២០០៧ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគោលនយោបាយជាតិស្តីពីសាលាកុមារមេត្រី ហើយក្របខណ្ឌសាលាកុមារមេត្រីត្រូវបានរៀបចំឡើងក្រោមកិច្ចសហការជាមួយអង្គការ UNICEF អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា និងអង្គការសង្គ្រោះកុមារន័រវេស ដើម្បីជាជំនួយក្នុងការកសាងឯកសារ និងការអនុវត្តសកម្មភាពសាលាកុមារមេត្រីនៅតាមសាលារៀន។

ក្របខណ្ឌនេះផ្តោតទៅលើសមាសភាគចំនួនប្រាំមួយដូចខាងក្រោម ៖

១. ការចូលរៀនប្រកបដោយសមធម៌

២. ប្រសិទ្ធភាពនៃការបង្រៀន និងរៀន

៣. សុខភាព សុវត្ថិភាព និងការការពារកុមារ

៤. ការឆ្លើយតបទៅនឹងយេនឌ័រ

៥. ការចូលរួមរបស់កុមារ មាតាបិតា និងសហគមន៍

៦. ការគាំទ្រពីប្រព័ន្ធអប់រំ ( ការដឹកនាំ និងគ្រប់គ្រង )។

គោលនយោបាយសាលាកុមារមេត្រីនេះ ត្រូវបានពង្រីកទៅដល់អនុវិទ្យាល័យនៅឆ្នាំ២០១៣។ ដូច្នេះសាលាកុមារមេត្រីគ្របដណ្តប់លើរយៈពេល៩ឆ្នាំនៃការអប់រំមូលដ្ឋាន។

នៅឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការ UNICEF រៀបចំការវាយតម្លៃការអនុវត្តសាលាកុមារមេត្រីក្នុងរយៈពេលដប់ឆ្នាំចុងក្រោយ ដោយក្រុមវាយតម្លៃដែលជាភាគីទីបី។ ផ្អែកលើអនុសាសន៍ខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការ UNICEF និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដាក់ចេញនូវអន្តរាគមន៍មួយចំនួនដូចខាងក្រោម ៖

១. ពង្រឹងអធិការកិច្ចបែបធានាគុណភាព (ផ្ទៃក្នុង និងផ្ទៃក្រៅ) ព្រមទាំងប្រើកុំព្យូទ័របន្ទះក្នុងការពិនិត្យតាមដាន និងវាយតម្លៃសាលាកុមារមេត្រី។

២. ពង្រឹងការអភិវឌ្ឍវិជ្ជាជីវៈនៅកម្រិតកម្រងសាលា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពបង្រៀន និងរៀននៅតាមសាលាដែលជាសមាជិក។

៣. ពង្រីកការអនុវត្តសាលាកុមារមេត្រីនៅមធ្យមសិក្សាបឋមភូមិ និងបឋមសិក្សា ដោយពិនិត្យឡើងវិញ និងកែលម្អក្របខណ្ឌសាលាកុមារមេត្រីនៅការអប់រំកម្រិតមូលដ្ឋាន។

៤. ពិនិត្យឡើងវិញ និងពង្រីកការអនុវត្តប្រព័ន្ធរម្លឹកជាមុន ដែលជាអន្តរាគមន៍ទប់ស្កាត់ការបោះបង់ការសិក្សាចំពោះសិស្សដែលមានបញ្ហាលើការសិក្សា និងគ្រួសារ។

គោលការណ៍ណែនាំ ស្តីពីប្រព័ន្ធរម្លឹកជាមុនសម្រាប់ទប់ស្កាត់សិស្សបោះបង់ការសិក្សាផ្អែកតាមការពិនិត្យឡើងវិញលើប្រព័ន្ធរម្លឹកជាមុន។ គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រីកការអនុវត្តប្រព័ន្ធរម្លឹកជាមុន នៅតាមសាលាអប់រំកម្រិតមូលដ្ឋានទាំងអស់ និងជាមគ្គុទេសក៍សម្រាប់នាយកសាលា និងគណៈគ្រប់គ្រងសាលារៀនទាំងអស់ដើម្បីលុបបំបាត់ការបោះបង់ការសិក្សា។ គោលការណ៍ណែនាំនេះជួយដល់សាលារៀនក្នុងការកំណត់អត្តសញ្ញាណសិស្ស ដែលងាយប្រឈមនឹងការបោះបង់ការសិក្សា តាមដានអវត្តមានសិស្ស និងលើកជាអន្តរាគមន៍ទប់ស្កាត់ការបោះបង់ការសិក្សា។

ក្នុងដំណើរការពិនិត្យឡើងវិញនេះ ក្រសួងអប់រំ យុវជន និងកីឡា សង្កេតឃើញថា ការអនុវត្តប្រព័ន្ធរម្លឹកជាមុននៅតាមគ្រឹះស្ថានមធ្យមសិក្សា ក្រោមគម្រោងសាកល្បងការទប់ស្កាត់ការបោះបង់ការសិក្សា ដែលជាគម្រោងស្រាវជ្រាវផ្តល់ជំនួយដោយ USAID និងអនុវត្តដោយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា និង Creative Associates ទទួលបានលទ្ធផលវិជ្ជមានក្នុងការទប់ស្កាត់សិស្សបោះបង់ការសិក្សានៅអនុវិទ្យាល័យ។ ដូច្នេះគោលការណ៍ណែនាំនេះផ្អែកលើមេរៀនពីគម្រោងស្រាវជ្រាវខាងលើ ដោយមានការកែសម្រួលជាច្រើន។ ជាពិសេសវាធ្វើឱ្យកាន់ប្រសើរនូវការងាររដ្ឋបាលនៃប្រព័ន្ធរម្លឹកជាមុនដើម្បីកាត់បន្ថយពេលវេលាដែលចំណាយក្នុងការបណ្តុះបណ្តាល ជាពិសេសដោយផ្តោតលើការប្រើប្រាស់ឧបករណ៍ដែលមានស្រាប់ដែលសាលារៀនភាគច្រើនក្រៅពីគម្រោងស្រាវជ្រាវកំពុងប្រើប្រាស់រួចហើយ ខណៈដែលនៅតែប្រើប្រាស់ ឬយកលំនាំតាមលិខិតគំរូមួយចំនួន និងឧបករណ៍មួយចំនួនដែលបានផ្តល់ជូននៅក្នុងគម្រោង SDPP។ គោលការណ៍ណែនាំនេះបានពង្រីកវិសាលភាពអន្តរាគមន៍ ដើម្បីរួមបញ្ចូលការអនុវត្តល្អបំផុតក្នុងការទប់ស្កាត់ការបោះបង់ការសិក្សានៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ ដែលត្រូវបានអនុវត្តដោយគម្រោងអង្គការមិនមែនរដ្ឋាភិបាល និងសាលាផ្សេងទៀត និងផ្តល់លទ្ធភាពឱ្យមានការកំណត់អាទិភាពយ៉ាងច្រើននៅកម្រិតសាលារៀន សំដៅធានាថា អាទិភាពទាំងនេះបំពេញតម្រូវការរបស់សិស្សនៅតាមសាលារៀននីមួយៗ។ គោលការណ៍ណែនាំនេះមិនមែនមានន័យថាជាបញ្ញត្តិបញ្ជានោះទេ ហើយគណៈគ្រប់គ្រងតាមសាលារៀនត្រូវបានលើកទឹកចិត្តធ្វើឱ្យប្រសើរឡើង ឬអនុវត្តនគំនិតផ្តួចផ្តើមតាមមូលដ្ឋានដទៃទៀតដែលទាក់ទងនឹងសហគមន៍ និងប្រើប្រាស់បំណិនជីវិតដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រធានបទនានាដែលសំដៅទៅលើតម្រូវការរបស់មូលដ្ឋាន និងភាពលំបាក។

# ២ ខ្លឹមសារសង្ខេបស្តីពីប្រព័ន្ធរម្លឹកជាមុន




ការកំណត់អត្តសញ្ញាណសិស្ស ដែលងាយប្រឈមនឹងការបោះបង់ការសិក្សាពីដើមឆ្នាំជួយឱ្យសាលារៀន និងសហគមន៍ត្រៀមខ្លួនបានល្អដើម្បីដោះស្រាយបញ្ហាប្រឈមរបស់សិស្សក្នុងការបញ្ចប់ការសិក្សារបស់ពួកគេ។ ការធ្វើអន្តរាគមន៍នៅដំណាក់កាលដំបូង ជាពិសេសនៅពេលសិស្សអវត្តមានពីការសិក្សា ជួយឱ្យពួកគេអាចត្រឡប់មកចូលរៀនវិញ និងរៀនទាន់សិស្សដទៃទៀត។ គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន មាតាបិតា និងអាជ្ញាធរមូលដ្ឋាន រៀបចំការទប់ស្កាត់ការបោះបង់ការសិក្សា ជាពិសេសសម្រាប់សិស្សដែលអវត្តមានញឹកញាប់។ កម្មវិធីនេះអាចជួយឱ្យសិស្សបន្តការសិក្សា និងសម្រេចបានគោលដៅបញ្ចប់ការសិក្សា ដែលមានកំណត់ក្នុងផែនការយុទ្ធសាស្រ្តអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ប្រព័ន្ធរម្លឹកជាមុនសម្រាប់ទប់ស្កាត់សិស្សបោះបង់ការសិក្សាគួរគប្បីរៀបចំដូចខាងក្រោម៖

## ២.១ ការបង្កើតគណៈកម្មការប្រព័ន្ធរម្លឹកជាមុន

នាយកសាលាគួរបង្កើតគណៈកម្មការប្រព័ន្ធរម្លឹកជាមុន។ គណៈកម្មការនេះគួរដឹកនាំដោយនាយកសាលាដោយមានការចូលរួមរបស់គ្រូបន្ទុកថ្នាក់ គណៈកម្មការទ្រទ្រង់សាលារៀន សហគមន៍ មាតាបិតា ក្រុមប្រឹក្សាកុមារ និងប្រធានថ្នាក់។

1 សាលារៀនខ្លះមានគណៈកម្មការមួយចំនួនដែលបង្កើតឡើងដើម្បីដោះស្រាយបញ្ហាលំបាករបស់សិស្សដូចជាទីប្រឹក្សាកុមារីប្រឹក្សាអាជីពក្រុមប្រឹក្សាយុវជនជាដើម។ វាជារឿងសំខាន់ដែលសាលារៀនធានាថាក្រុមការងារទាំងនេះដំណើរការទាំងអស់គ្នាដើម្បីធានាថាតម្រូវការសិស្ស ត្រូវបានដោះស្រាយទូលំទូលាយ។

គណៈកម្មការនេះគួររៀបចំកិច្ចប្រជុំតម្រង់ទិសដើម្បី ៖

- ពិភាក្សាពីគោលបំណងនៃប្រព័ន្ធរម្លឹកជាមុន
- កំណត់អត្តសញ្ញាណសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា
- គ្រោងប្រព័ន្ធតាមដានការរម្លឹកជាមុន
- ឯកភាពលើការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីតាមដានអវត្តមានសិស្ស
- ឯកភាពលើពេលវេលា និងវិធីល្អបំផុតក្នុងការបង្កើនការយល់ដឹងពីសារៈសំខាន់របស់កុមារដែលបញ្ចប់យ៉ាងហោចណាស់ការអប់រំមូលដ្ឋាន និងច្បាប់ស្តីពីពលកម្មកុមារដល់មាតាបិតា សិស្ស និងសហគមន៍
- បង្កើតអន្តរាគមន៍ក្នុងសាលាទៅតាមតម្រូវការរយៈពេលវែងជាបន្តបន្ទាប់របស់សិស្ស  ដែលជួបទប់ស្កាត់មិនឱ្យសិស្សបោះបង់ការសិក្សា។

## ២.២ ការកំណត់អត្តសញ្ញាណសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា

មានកត្តាជាច្រើនដែលជួយបង្កើនលទ្ធភាពដែលកុមារបោះបង់ការសិក្សា។ ការកំណត់អត្តសញ្ញាណសិស្សដែលងាយប្រឈមនឹងបោះបង់ការសិក្សា ធ្វើឱ្យគ្រូបង្កើនយកចិត្តទុកដាក់ជាពិសេសក្នុងថ្នាក់ និងសាលា ហើយសហគមន៍អាចផ្តល់អន្តរាគមន៍ជួយកាត់បន្ថយហានិភ័យនៃការបោះបង់ការសិក្សាបាន។

ដោយមានជំនួយពីគ្រូមុខវិជ្ជា គ្រូបន្ទុកថ្នាក់ នាយកសាលា និងអ្នកដឹកនាំសហគមន៍គួរវាយតម្លៃសិស្សម្នាក់ៗធៀបនឹងលក្ខណវិនិច្ឆ័យនៃ “សូចនាករហានិភ័យ” សំខាន់ៗ ដូចខាងក្រោម ៖

### សូចនាករហានិភ័យនៃការបោះបង់ការសិក្សា

- **អវត្តមាន ៖** អវត្តមានពីការសិក្សាមានន័យថា សិស្សងាយនឹងរៀនមិនទាន់គេ។
- **លទ្ធផលសិក្សា** ដូចជា ពិន្ទុអំណានថ្នាក់ដំបូង ពិន្ទុតេស្តប្រចាំខែ លទ្ធផលតេស្តប្រចាំឆមាស និងលទ្ធផលតេស្តចុងឆ្នាំ។ សិស្សរៀនយឺតងាយនឹងរៀនមិនទាន់គេ និងបោះបង់ការសិក្សា។ ជំនាញទាបផ្នែកអំណាន និងគណិតវិទ្យាមូលដ្ឋាន អាចបង្កជាបញ្ហាចោទ និងគួរដោះស្រាយភ្លាមៗ។
- សិស្សដែលមាន**អាយុច្រើន**ធៀបនឹងកម្រិតថ្នាក់របស់ខ្លួន
- **ចម្ងាយពីផ្ទះ**ទៅសាលា តើពួកគេមានមធ្យោបាយធ្វើដំណើរឬទេ ហើយមានសុវត្ថិភាពតាមផ្លូវដែរឬទេ។
- ការវាយតម្លៃរបស់គ្រូបន្ទុកថ្នាក់លើ**ឥរិយាបថរបស់សិស្ស។**
- **ពិការភាព**
- **របួស ឬជំងឺ**ដែលរារាំងមិនឱ្យកុមាររៀនសូត្របានយូរ
- **បងប្អូនបង្កើតផ្សេងទៀត**ដែលធ្លាប់បោះបង់ការសិក្សា ឬកុមារមកពីគ្រួសារធំ
- **កុមារកំព្រា** ឬកុមារមកពីគ្រួសារដែលមានតែឪពុក/ម្តាយ ឬកុមារដែលមិនរស់នៅជាមួយឪពុកម្តាយ
- **ឪពុក/ម្តាយឈឺ** ជាពិសេសនៅពេលកុមារត្រូវធ្វើជាអ្នកថែទាំ។
- **ស្ថានភាពគ្រួសារ** (សេដ្ឋកិច្ច ហិង្សា ជនជាតិដើមភាគតិច...)
- **ឪពុកម្តាយមិនចុះហត្ថលេខា**លើសៀវភៅតាមដានការសិក្សា

សិស្សដែលមានកត្តាហានិភ័យច្រើន ងាយប្រឈមនឹងការបោះបង់ការសិក្សា និងត្រូវការការយកចិត្តទុកដាក់បន្ថែមជាពិសេស ដើម្បីអាចឱ្យពួកគេបញ្ចប់ការអប់រំមូលដ្ឋានបាន។

គ្រូបន្ទុកថ្នាក់ គួរប្រើប្រាស់ "តារាងកំណត់អត្តសញ្ញាណសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា" (ឧបសម្ព័ន្ធ ៥.២) ដើម្បីរៀបរាប់ពីសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា។ គួរកត់សម្គាល់ថា សិស្សដែលមិនទំនងជាបោះបង់ការសិក្សានៅដើមឆ្នាំសិក្សា អាចក្លាយជាសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា ប្រសិនបើមានកាលៈទេសៈប្រែប្រួល។ ឧ. គ្រោះថ្នាក់ជំងឺធ្ងន់ធ្ងរដែលកើតមានលើសិស្ស ឬឪពុក/ម្ដាយរបស់ពួកគេអាចធ្វើឱ្យសិស្សដែលធ្លាប់តែពូកែរៀនមិនទាន់គេ និងបោះបង់ការសិក្សា។ ដូច្នេះ គ្រូបង្រៀនត្រូវបន្តធ្វើបច្ចុប្បន្នភាពកំណត់សម្គាល់របស់ខ្លួនលើសិស្សដែល "ងាយប្រឈមនឹងការបោះបង់ការសិក្សា" យ៉ាងហោចណាស់រៀងរាល់ខែ។

## ២.៣ រៀបចំអន្តរាគមន៍ដើម្បីជួយដល់សិស្សដែលប្រឈមក្នុងរយៈពេលវែង

ក្នុងអំឡុងពេលរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ សាលារៀនគួរវិភាគទិន្នន័យដែលប្រមូលបានក្នុងកំឡុងពេលរៀបចំសាលារៀន ការចុះឈ្មោះចូលរៀន ការតម្រង់ទិសការឆ្លងភូមិសិក្សា (ចូលថ្នាក់ទី៧) ការប្រជុំប្រចាំខែ ក៏ដូចជាទិន្នន័យដែលមាននៅក្នុង "ការកំណត់អត្តសញ្ញាណសិស្សដែលមានហានិភ័យក្នុងបញ្ជីបោះបង់" (សូមមើលឧបសម្ព័ន្ធ ៥.២)។ បន្ទាប់មកវាគួរត្រូវបានប្រើដើម្បីជួយកំណត់នូវអ្វីដែលជាតម្រូវការទូទៅរបស់សិស្សប្រឈម ដូច្នេះពួកគេអាចរៀបចំផែនការអន្តរាគមន៍ដែលសមស្របបំផុតដើម្បីជួយទប់ស្កាត់ការបោះបង់ការសិក្សានិងធានាថាកុមារចុះឈ្មោះចូលសាលារៀនរបស់ពួកគេ។

បញ្ជីអន្តរាគមន៍ទូទៅដែលអាចត្រូវបានប្រើ ដើម្បីគាំទ្រដល់តម្រូវការជាបន្តបន្ទាប់របស់សិស្សដែលមានប្រឈមនឹងការបោះបង់ការសិក្សាអាចរកឃើញនៅក្នុងផ្នែក ៤.២។ "ការធ្វើអន្តរាគមន៍រយៈពេលវែងដើម្បីជួយទប់ស្កាត់ការបោះបង់ចោលការសិក្សា" ក្រុមការងារគ្រប់គ្រងតាមសាលារៀនត្រូវបានលើកទឹកចិត្តឱ្យសម្របខ្លួន ឬអនុវត្តន៍គំនិតផ្តួចផ្តើមក្នុងតំបន់ផ្សេងទៀតដែលទាក់ទងនឹងសហគមន៍មូលដ្ឋាន ឬប្រើប្រាស់បំណិនជីវិតដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រធានបទនានាដែលសំដៅទៅលើតម្រូវការ និងភាពលំបាកក្នុងមូលដ្ឋាន។

## ២.៤ ការតាមដានសិស្ស និងអវត្តមានសិស្ស

ដោយមានជំនួយពីប្រធានថ្នាក់ គ្រូបន្ទុកថ្នាក់គួរពិនិត្យតាមដានវត្តមាន ឥរិយាបថ និងកិច្ចការរបស់សិស្សទាំងអស់ពេញមួយឆ្នាំសិក្សា។ ប្រធានថ្នាក់គួរជូនដំណឹងដល់គ្រូបន្ទុកថ្នាក់យ៉ាងហោចណាស់រាល់សប្តាហ៍អំពីសិស្សដែលអវត្តមាន ៣ ដងឡើងទៅ/សប្តាហ៍។

គួរមានយកចិត្តទុកដាក់ និងការតាមដានក្នុងថ្នាក់រាល់ថ្ងៃលើសិស្សដែលគ្រូបានកំណត់អត្តសញ្ញាណថា "ងាយប្រឈមនឹងការបោះបង់ការសិក្សា" ដើម្បីឱ្យពួកគេរៀនទាន់គេ កត់សម្គាល់ថាតើពួកគេរៀនទាន់គេ ឬទេ និងផ្តល់ការប្រឹក្សាដល់សិស្សដែលមានការលំបាកនៅសាលា ឬផ្ទះ។

មានសៀវភៅកំណត់ត្រា ៣ ដែលគ្រូត្រូវបំពេញ ដើម្បីតាមដានសិស្សពេញមួយឆ្នាំសិក្សា និងទប់ស្កាត់ការបោះបង់ការសិក្សា៖

## ១. បញ្ជីហៅឈ្មោះសិស្ស






## ២. បញ្ជីស្រង់ពិន្ទុ






## ៣. សៀវភៅតាមដានការសិក្សា







ដើម្បីជួយដល់ការតាមដានសិស្សទាំងអស់ និងទប់ស្កាត់ការបោះបង់ការសិក្សា គ្រូបន្ទុកថ្នាក់ (ដោយមានជំនួយពីប្រធានថ្នាក់) គួរ ៖




- កត់ត្រាក្នុងកូឡោនសេចក្តីផ្សេងៗក្នុងបញ្ជីវត្តមានសិស្ស ថាតើមានសិស្សដែលងាយប្រឈម នឹងការបោះបង់ការសិក្សា ឬត្រូវការការយកចិត្តទុកដាក់ពិសេស ឬទេ និងត្រូវធ្វើយ៉ាងណាឱ្យពួកគេទទួលបានការតាមដាន និងជំនួយក្នុងថ្នាក់។
- កត់ត្រាអវត្តមានរៀងរាល់ថ្ងៃ (សម្រាប់អនុវិទ្យាល័យ កិច្ចការនេះគួរធ្វើឡើងតាមមុខវិជ្ជា ដោយមានជំនួយពីប្រធានថ្នាក់)។ សិស្សម្នាក់ត្រូវបានរាប់ថាអវត្តមាន ទោះបីជាពួកគេមិនបានរៀនតែមួយមេរៀនក្តី។
- ប្រធានថ្នាក់គួរជួបជាមួយគ្រូបន្ទុកថ្នាក់យ៉ាងតិចរៀងរាល់សប្តាហ៍ ដើម្បីជូនដំណឹងប្រសិនបើសិស្សម្នាក់អវត្តមានចាប់ពី ៣ ដងឡើងទៅ/សប្តាហ៍ ឬ ៦ ដងឡើងទៅ/ខែ។
- គ្រូបន្ទុកថ្នាក់គួរធ្វើបច្ចុប្បន្នភាពបញ្ជីវត្តមានសិស្ស យ៉ាងហោចណាស់រៀងរាល់ខែ និងពិនិត្យថាតើមានសិស្សផ្សេងទៀតដែលអាចត្រូវការជំនួយ ឬទេ។
- គ្រូបន្ទុកថ្នាក់ គួរធ្វើបច្ចុប្បន្នភាពតារាងស្រង់ពិន្ទុរបស់សិស្សយ៉ាងហោចណាស់រៀងរាល់ខែ និងពិនិត្យថាតើមានសិស្សផ្សេងទៀតដែលអាចត្រូវការជំនួយ ឬទេ។

- គ្រូបន្ទុកថ្នាក់គួរបំពេញសៀវភៅតាមដានការសិក្សា រួចផ្ញើទៅផ្ទះឱ្យមាតាបិតាចុះហត្ថលេខា និងបញ្ជាក់ថាមានបញ្ហាចោទ ឬទេ។
- សាលារៀនគួរពិភាក្សាពីវឌ្ឍនភាពរបស់សិស្ស ដែលងាយប្រឈមនឹងការបោះបង់ការសិក្សាក្នុងកិច្ចប្រជុំប្រចាំខែ និងពិចារណាថាតើសាលាបានផ្តល់ជំនួយគ្រប់គ្រាន់ដើម្បីទប់ស្កាត់សិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា ឬទេ និងរាយការណ៍ពីសិស្សដែលអវត្តមានលើស ៦ ដង/ខែ។
- សម្រាប់សិស្សដែលបង្កការព្រួយបារម្ភខ្លាំង ជាពិសេសសិស្សដែលអវត្តមានលើស ១០ថ្ងៃ/ខែ ឬសិស្សដែលមានការប្រែប្រួលឥរិយាបថគួរឱ្យព្រួយបារម្ភ គួរមានការរៀបចំកិច្ចប្រជុំការរៀបចំករណីជាមួយសិស្ស មាតាបិតា និងគ្រូបន្ទុកថ្នាក់ និង/ឬនាយកសាលា។

## ២.៥ ការស្វែងយល់ពីសកម្មភាពឆ្លើយតបបឋម

សកម្មភាពឆ្លើយតបបឋមត្រូវបានធ្វើឡើងសម្រាប់សិស្ស ដែលស្តែងឱ្យឃើញនូវបញ្ហាភ្លាមៗ ឬការលំបាកក្នុងការសិក្សារបស់ខ្លួន។ គ្រូបន្ទុកថ្នាក់គួរផ្តួចផ្តើមសកម្មភាព "ឆ្លើយតបបឋម" នៅពេលដែលសិស្ស ៖

- អវត្តមាន ៣ដងឡើងទៅ/សប្តាហ៍ ឬ ៦ដងឡើងទៅ/ខែ។
- មានពិន្ទុទាប
- មានឥរិយាបថមិនល្អនៅក្នុង ឬក្រៅថ្នាក់
- បែកអារម្មណ៍ មិនសប្បាយចិត្ត ឬមិនសូវផ្តោតអារម្មណ៍បានល្អ
- មិនសូវជាមានមិត្តភក្តិ និងដាច់ឆ្ងាយពីសិស្សផ្សេងទៀត។

ប្រព័ន្ធឆ្លើយតបបឋមមានចាប់ពីការនិយាយជាមួយសិស្ស ដើម្បីស្វែងយល់ពីការលំបាករបស់ពួកគេ ការយកចិត្តទុកដាក់បន្ថែមក្នុងថ្នាក់ ការទាក់ទងទៅមាតាបិតាសិស្សតាមរយៈការផ្ញើសំបុត្រ ទូរស័ព្ទ និង/ឬ ការចុះតាមផ្ទះដោយគ្រូ នាយកសាលា ឬសមាជិកសហគមន៍ រហូតដល់កិច្ចប្រជុំគ្រប់គ្រងករណីជាមួយបុគ្គលិកសាលា សិស្ស និងមាតាបិតា។

សកម្មភាពឆ្លើយតបបឋមមួយចំនួនមានបង្ហាញក្នុងផ្នែក ៤.១ ៖ សកម្មភាពឆ្លើយតបបឋម

ក្រៅពីនេះ សាលារៀនត្រូវមានផែនការ និងរៀបចំសកម្មភាពជាច្រើនផ្សេងទៀតដើម្បីជួយបំពេញតម្រូវការរយៈពេលវែងរបស់សិស្ស និងទប់ស្កាត់ការបោះបង់ការសិក្សា ដូចមានក្នុង២.៣ រៀបចំអន្តរាគមន៍ដើម្បីជួយដល់សិស្សដែលប្រឈមនឹងហានិភ័យដែលត្រូវការរយៈពេលវែង។ សកម្មភាពមួយចំនួនមានបង្ហាញក្នុងផ្នែក ៤.២ អន្តរាគមន៍រយៈពេលវែងផ្សេងទៀតដើម្បីជួយទប់ស្កាត់សិស្សបោះបង់ការសិក្សា។

## ២.៦ ការបង្កើនការយល់ដឹង និងការតស៊ូមតិក្នុងសហគមន៍

សំខាន់បំផុតត្រូវបង្កើនការយល់ដឹងពីបញ្ហាបោះបង់ការសិក្សា អត្ថប្រយោជន៍នៃការសិក្សា និងសិទ្ធិរបស់កុមារក្នុងការបញ្ចប់យ៉ាងហោចណាស់ការអប់រំមូលដ្ឋាន ដើម្បីឱ្យពួកគេជួយផ្តល់ដំណោះស្រាយក្នុងមូលដ្ឋានដែលជួយឱ្យសិស្សបន្តការសិក្សា។ គណៈកម្មការទប់ស្កាត់ការបោះបង់ការសិក្សា គួររិះរកវិធីជូនដំណឹងដល់មាតាបិតា សិស្ស គ្រូបង្រៀន និងសហគមន៍ស្តីពី ៖

## ២.៦.១ ច្បាប់សំខាន់ៗនៅកម្ពុជាដែលធានាសិទ្ធិទទួលបានការអប់រំរបស់កុមារ

- រដ្ឋធម្មនុញ្ញកម្ពុជាបានធានានូវសិទ្ធិរបស់កុមារគ្រប់រូប ក្នុងការបញ្ចប់យ៉ាងហោចណាស់ការអប់រំមូលដ្ឋាន។
- ច្បាប់កម្ពុជារិតត្បិតចំនួនម៉ោងស្របច្បាប់ដែលកុមារអាចធ្វើការបាន។ យោងតាមច្បាប់ស្តីពីការងារ កុមារដែលមានអាយុ ៥-១១ ឆ្នាំ អាចធ្វើការរហូតដល់ ១ ម៉ោង/សប្តាហ៍។ កុមារដែលមានអាយុ ១២-១៤ ឆ្នាំអាចធ្វើការងារស្រាលរហូតដល់ ១២ ម៉ោង/សប្តាហ៍ ប្រសិនបើការងារនោះមិនបង្កគ្រោះថ្នាក់ដល់សុខភាព ឬការអភិវឌ្ឍរាងកាយរបស់កុមារ និងមិនរំខានដល់ការសិក្សារបស់កុមារ។កុមារអាយុ១៥-១៧ឆ្នាំអាចធ្វើការរហូតដល់៤៨ម៉ោង/សប្តាហ៍[2]ប្រសិនបើការងារនោះអាចអនុញ្ញាតបាន និងមិនបង្កគ្រោះថ្នាក់។
- សហគមន៍គួរយល់ពីភាពខុសគ្នារវាងកិច្ចការផ្ទះ ការងារ និងការងារគ្រោះថ្នាក់។ តាមច្បាប់ អ្នកមានអាយុក្រោម ១៨ មិនត្រូវបានអនុញ្ញាតឱ្យធ្វើការងារគ្រោះថ្នាក់ឡើយ[3] ហើយកុមារអាយុរហូតដល់ ១៤ ឆ្នាំ មិនត្រូវបានអនុញ្ញាតឱ្យពាក់ព័ន្ធក្នុងការងារដែលរំខានដល់ការសិក្សារបស់ពួកគេនោះទេ។

## ២.៦.២ អត្ថប្រយោជន៍នៃការអប់រំ និងសារៈសំខាន់នៃការចុះឈ្មោះចូលរៀននៅអាយុត្រឹមត្រូវ

មាតាបិតា និងអាណាព្យាបាលទាំងអស់គួរដឹងថា ៖




- កុមារត្រូវចូលរៀនថ្នាក់បឋមសិក្សានៅអាយុត្រឹមត្រូវ (៦ ឆ្នាំ) ទោះបីជាពួកគេមានរូបរាងតូចជាវ័យក្តី ព្រោះសិស្សធម្មតាកាន់តែងាយបោះបង់ការសិក្សានៅថ្នាក់បន្តបន្ទាប់។
- ការចូលរៀនថ្នាក់មត្តេយ្យ ឬមុនមត្តេយ្យ (ប្រសិនបើមាន) ជួយបង្កើនលទ្ធភាពដែលសិស្សបញ្ចប់ការអប់រំមូលដ្ឋាន ហើយមាតាបិតាត្រូវបញ្ជូនកូនឱ្យចូលរៀនថ្នាក់មុនមត្តេយ្យ (ប្រសិនបើមានក្នុងតំបន់នោះ)។
- អត្ថប្រយោជន៍នៃការអប់រំ ជាពិសេសពាក់ព័ន្ធនឹងការងារនៅថ្ងៃខាងមុខ និងប្រាក់ឈ្នួលសមរម្យ សមត្ថភាពរបស់ពួកគេ ក្នុងការសម្របតាមការប្រែប្រួល សុខភាពរយៈពេលវែង បញ្ចៀសគ្រោះថ្នាក់នៃការបោកបញ្ឆោត ការកេងប្រវ័ញ្ច ឬការជួញដូរ និងអាចចូលរួមពេញលេញក្នុងសកម្មភាពទាំងអស់ក្នុងសង្គម។
- វាក៏មានសារៈសំខាន់ផងដែរដើម្បីឱ្យយល់ដឹងអំពីការផ្លាស់ប្តូរនៃពិភពលោក/ប្រទេសហើយថាពិភពការងារកំពុងផ្លាស់ប្តូរក្នុងល្បឿនលឿន និងបច្ចេកវិទ្យាថ្មីៗ ជាច្រើនកំពុងត្រូវបានគេណែនាំ។ នេះមានន័យថាប្រភេទការងារដែលមនុស្សវ័យក្មេងនឹងធ្វើនៅពេលអនាគតក៏នឹងផ្លាស់ប្តូរផងដែរ។ ដូច្នេះវាសំខាន់ណាស់ដែលពួកគេរៀនជំនាញផ្សេងៗ ជាពិសេសជំនាញទន់ និងគំនិតច្នៃប្រឌិត និងជំនាញដោះស្រាយបញ្ហា ដែលពួកគេត្រូវការដើម្បីអាចសម្របខ្លួនទៅនឹងការផ្លាស់ប្តូររបស់ពិភពលោក។

---

2 កម្រិតទាំងនេះសំដៅលើសកម្មភាពសេដ្ឋកិច្ចណាមួយ និងមិនរួមបញ្ចូលកិច្ចការផ្ទះស្រាលៗ ដូចជា ការបោសសម្អាត។

3 ការងារគ្រោះថ្នាក់ត្រូវបានកំណត់និយមន័យក្នុងច្បាប់កម្ពុជា និងរួមមានការងារក្រោមដី ការលើកដាក់ ការយួរ/កាន់ ឬផ្លាស់ទីបន្ទុកធ្ងន់ៗ ការងារនេសាទក្នុងសមុទ្រជ្រៅ និងឆ្ងាយពីឆ្នេរ ការងារនៅជិតឡដុត ឬឡចំហុយសម្រាប់ផលិតកែវ សេរ៉ាមិក ឬឥដ្ឋ ការពន្លត់ភ្លើង សំណង់ ឬការងារវាយកម្ទេច ការងារពាក់ព័ន្ធនឹងការប៉ះពាល់សារធាតុគីមី ការងារក្នុងទីដែលមានសីតុណ្ហភាពខ្ពស់ និងការរៀបចំទុកដាក់ ឬបាញ់ថ្នាំសម្លាប់សត្វល្អិត និងថ្នាំសម្លាប់ស្មៅ ការងារពេលយប់នៅចន្លោះម៉ោង ១០ យប់ និង ៥ ព្រឹក។ និយោជកអាចស្នើសុំទៅនាយកដ្ឋានការងារឲ្យអនុញ្ញាតឲ្យកុមារអាយុ ១៦ ឆ្នាំធ្វើការងារគ្រោះថ្នាក់ ប្រសិនបើមានការធានាការពារសុខភាព សុវត្ថិភាព និងសីលធម៌របស់កុមារ ហើយនិយោជកអាចផ្តល់ការបណ្តុះបណ្តាលសមស្រប។

## ២.៦.៣ ការចូលរួមចំណែករបស់មាតាបិតាដល់ការបញ្ចប់ការសិក្សារបស់កូន

គណៈកម្មការទ្រទ្រង់សាលារៀនគួរធានាថា មាតាបិតា សិស្ស និងសហគមន៍ដឹងពីអ្វីដែលពួកគាត់អាចធ្វើបាននៅកម្រិតគ្រួសារដើម្បីធានាថា កូនមានសុខភាពល្អ អាចផ្តោត លើការសិក្សា និងបញ្ចប់ការអប់រំមូលដ្ឋានដោយជោគជ័យ។ ជាពិសេសពួកគាត់គួរដឹងពី៖

- វិន័យ និងការរំពឹងទុករបស់សាលាដើម្បីប្រាកដថាកូនៗរបស់ពួកគេស្គាល់។
- ពួកគេក៏ត្រូវដឹងអំពីសិទ្ធិជាមូលដ្ឋានដែលពួកគេអាចរំពឹងទុកសម្រាប់ការអប់រំមូលដ្ឋានដែលកំណត់ដោយក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។ ទាំងនេះរួមបញ្ចូលទាំង៖
    - សាលារៀនឥតបង់ថ្លៃសម្រាប់ក្មេងចាប់ពីអាយុ ៦ឆ្នាំ ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៩។
    - គ្រូបង្រៀនម្នាក់ សម្រាប់ថ្នាក់នីមួយៗនិងសិស្ស ៤២ នាក់
    - ២២៨ ថ្ងៃនៃការសិក្សា
    - ផ្តល់កម្ពីសៀវភៅដល់សិស្សគ្រប់រូប ៣ក្បាល ថ្នាក់ទី១ ដល់ទី៣ និង ៤ក្បាលពីថ្នាក់ទី៤ ដល់ទី៦
    - គ្រូនឹងជួយសិស្សទាំងអស់ឲ្យរៀន។




- វាអាចមានប្រយោជន៍ដើម្បីបង្ហាញផ្ទាំងរូបភាពដែលផលិតដោយ NCDD នៅក្នុងសាលារៀនរបស់អ្នក។ ព័ត៌មានបន្ថែមអាចរកនៅលើគេហទំព័ររបស់គ.ជ.អ.ប www.ncdd.gov.kh ។
- សេវាកម្មអ្វីខ្លះ និងសកម្មភាពសាលារៀនមាននិងពេលវេលាសំខាន់ៗសម្រាប់ការប្រឹក្សាយោបល់របស់មាតាបិតា និងការផ្តល់ព័ត៌មានត្រឡប់
- សារៈសំខាន់នៃអាហារូបត្ថម្ភល្អប្រសើរ ដើម្បីធានាថា សិស្សមានការអភិវឌ្ឍល្អ និងការផ្តល់អាហារពេលព្រឹកដើម្បីឱ្យសិស្សអាចផ្តោតអារម្មណ៍បានល្អលើការសិក្សា
- សារៈសំខាន់នៃការរក្សាអនាម័យល្អប្រសើរ ជាពិសេសការលាងសម្អាតដៃជាប្រចាំ និងក្រោយពេលប្រើប្រាស់បង្គន់ និងមុនពេលញ៉ាំអាហារ ការលាងសម្អាតបន្លែបានសមស្រប ការស្លៀកសម្លៀកបំពាក់ស្អាត និងការរក្សាអនាម័យក្នុងផ្ទះ។ មានការបញ្ជាក់យ៉ាងច្បាស់ថា កង្វះអនាម័យអាចបង្កជំងឺរាករូស និងជំងឺផ្លូវដង្ហើម ដែលធ្វើឱ្យសិស្សអវត្តមាន និងរៀនរៀនយឺត។
- មាតាបិតាគួរជូនដំណឹងដល់សាលាប្រសិនបើសិស្សត្រូវអវត្តមាន ជាពិសេសប្រសិនបើត្រូវអវត្តមានលើសពីមួយថ្ងៃ។
- វត្តមានទៀងទាត់ជាប្រការសំខាន់សម្រាប់ឱ្យសិស្សបញ្ចប់ការសិក្សា ដោយជោគជ័យ ហើយសាលានឹងទាក់ទងទៅពួកគាត់ប្រសិនបើសិស្សអវត្តមាន ៣ ដងឡើងទៅ/សប្តាហ៍។

- មាតាបិតាគួរយកចិត្តទុកដាក់លើការសិក្សារបស់សិស្ស និងធ្វើយ៉ាងណាឱ្យសិស្សមានពេលវេលាគ្រប់គ្រាន់ចូលរួមក្នុងក្លឹបសិក្សា និងនៅកន្លែងស្ងប់ស្ងាត់ដែលមានពន្លឺគ្រប់គ្រាន់ដើម្បីរម្លឹកមេរៀន ឬធ្វើកិច្ចការសាលា។
- មាតាបិតានឹងបានទទួល និងត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើសៀវភៅតាមដានការសិក្សារៀងរាល់ខែ និងពិភាក្សាពីកង្វល់នានាលើវឌ្ឍនភាពរបស់កុមារ ជាមួយគ្រូបន្ទុកថ្នាក់។
- ជូនដំណឹងដល់គ្រូបន្ទុកថ្នាក់ ឬនាយកសាលាប្រសិនបើកូនរបស់អ្នកមានបញ្ហា ឬការលំបាកក្នុងការសិក្សា ឬធ្វើកិច្ចការសាលាដើម្បីឱ្យពួកគេអាចជួយរកដំណោះស្រាយ។
- លើកទឹកចិត្តកូនរបស់ពួកគេនៅពេលពួកគេធ្វើបានល្អនៅសាលារៀន។ គាំទ្រនិងសួរកូនរបស់ពួកគេប្រសិនបើពួកគេមានការលំបាកណាមួយប្រសិនបើពួកគេធ្វើមិនបានល្អ។

សាលាគួរជូនដំណឹងដល់មាតាបិតា សហគមន៍ គ្រូបង្រៀន និងសិស្សថា ពួកគេត្រូវសហការគ្នាធ្វើយ៉ាងណាឱ្យសិស្សគ្រប់រូបបញ្ចប់ការអប់រំមូលដ្ឋាន ហើយពួកគេគួររៀបរាប់ពីជំនួយក្នុងសហគមន៍សម្រាប់សកម្មភាពតស៊ូមតិ និងសកម្មភាពឆ្លើយតបបឋម។

សាលារៀនគួរផ្សព្វផ្សាយទូលំទូលាយដល់សិស្ស មាតាបិតា និងសហគមន៍ពីសេវាគាំទ្រមានស្រាប់ដើម្បីជួយឱ្យកុមារបន្តការសិក្សា។

# ៣ តួនាទីរបស់អ្នកពាក់ព័ន្ធ

## ៣.១ អ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន

សាលារៀន និងសហគមន៍គួរចូលរួមក្នុងការអនុវត្តប្រព័ន្ធរម្លឹកជាមុនសម្រាប់ទប់ស្កាត់សិស្សបោះបង់ការសិក្សា។ តារាងខាងក្រោមរៀបរាប់ពីការទទួលខុសត្រូវសំខាន់ៗ។ គួរប្រើប្រាស់តារាងនេះនៅពេលបង្កើតប្រព័ន្ធរម្លឹកជាមុន ដើម្បីឱ្យអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានទាំងអស់យល់ច្បាស់ពីការទទួលខុសត្រូវរបស់ខ្លួន។

| អ្នកទទួលខុសត្រូវ | សកម្មភាព | ឯកសារ |
|---|---|---|
| ៣.១.១ គ្រូបន្ទុកថ្នាក់ | **១. កំណត់អត្តសញ្ញាណសិស្ស "ដែលងាយប្រឈមនឹងការបោះបង់ការសិក្សា"** ៖ សហការជាមួយអ្នកពាក់ព័ន្ធ នៅដើមឆ្នាំសិក្សាដើម្បីធានាថា ពួកគេមានបញ្ជីឈ្មោះសិស្សក្នុងថ្នាក់ដែលងាយប្រឈមនឹងការបោះបង់ការសិក្សាបំផុតនិងកត់ត្រាក្នុងកូឡោនសេចក្តីផ្សេងៗនៃបញ្ជីវត្តមាន(ផ្នែក២.២) ដើម្បីជួយរម្លឹកពួកគេឱ្យតាមដានបន្តលើសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សាឱ្យបានលឿនបំផុត។ | - ការកំណត់អត្តសញ្ញាណសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សានៅដើមឆ្នាំសិក្សា (ឧបសម្ព័ន្ធ ៥.២) |
| | **២.កត់ត្រាអវត្តមានរៀងរាល់ថ្ងៃ៖** ត្រូវកត់ត្រាអវត្តមានរៀងរាល់ថ្ងៃ (សម្រាប់អនុវិទ្យាល័យ កិច្ចការនេះគួរធ្វើតាមមុខវិជ្ជា) ដោយមានការគាំទ្រពីប្រធានថ្នាក់។ សិស្សម្នាក់ត្រូវបានរាប់ថាអវត្តមាន ទោះបីជាពួកគេមិនបានរៀនតែមួយមេរៀនក្តី។ | - បញ្ជីហៅឈ្មោះសិស្ស |
| | **៣. ធ្វើបច្ចុប្បន្នភាពបញ្ជីវត្តមានសិស្ស និងតារាងស្រង់ពិន្ទុយ៉ាងហោចណាស់រៀងរាល់ខែ** ៖ គ្រូបន្ទុកថ្នាក់គួរធ្វើបច្ចុប្បន្នភាពបញ្ជីវត្តមាន និងតារាងស្រង់ពិន្ទុយ៉ាងហោចណាស់រៀងរាល់ខែ និងពិនិត្យថាតើមានសិស្សផ្សេងទៀតដែលត្រូវការជំនួយ ឬទេ (ដោយសហការជាមួយគ្រូមុខវិជ្ជា នៅកម្រិតមធ្យមសិក្សា) បន្ថែមកំណត់សម្គាល់ក្នុងកូឡោនសេចក្តីផ្សេងៗ និងសរសេរបន្ថែមចំណុចទាំងនោះ ក្នុងបញ្ជីឈ្មោះសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា។ | - តារាងស្រង់ពិន្ទុ |
| | **៤. យកចិត្តទុកដាក់ជាពិសេសលើសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា** ៖ យកចិត្តទុកដាក់លើការតាមដានសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា (ផ្នែក ២.៤)។ | |

| អ្នកទទួលខុសត្រូវ | សកម្មភាព | ឯកសារ |
|---|---|---|
| | **៥. សៀវភៅតាមដានការសិក្សា** ៖ បំពេញសៀវភៅតាមដានការសិក្សា រួចផ្ញើទៅផ្ទះឱ្យមាតាបិតាចុះហត្ថលេខា និងកត់សម្គាល់ប្រសិនបើមានបញ្ហាណាមួយ។ | - សៀវភៅតាមដានការសិក្សា |
| | **៦. តាមដានសិស្សអវត្តមាន** ៖ តាមដានសិស្សក្នុងថ្នាក់ប្រសិនបើពួកគេអវត្តមានលើស ៣ដង/សប្តាហ៍ ឬលើស ៦ដង/ខែ។ | - លេខទូរស័ព្ទរបស់មាតាបិតា ឬអាណាព្យាបាល<br>- សៀវភៅទំនាក់ទំនងមាតាបិតាសិស្ស |
| | **៧. តាមដានជាមួយមាតាបិតាសិស្ស** ៖ ពិភាក្សាជាមួយនាយកសាលាពីករណីសិស្សដែលបោះបង់ការសិក្សា ជាពិសេសសិស្សដែលអវត្តមាន ១0ដងឡើងទៅ/ខែ ដើម្បីរៀបចំអន្តរាគមន៍ ដូចជាទូរស័ព្ទទៅមាតាបិតា ឬចុះដល់ផ្ទះឬអញ្ជើញឱ្យចូលរួមកិច្ចប្រជុំ។ល។ | - សៀវភៅកត់ត្រាដើម្បីកត់ត្រារាល់អន្តរាគមន៍ជាមួយសិស្ស ឬមាតាបិតា ( ឧបសម្ព័ន្ធ៥.១ ៖ ទម្រង់របាយការណ៍ចុះតាមផ្ទះ និង ឧបសម្ព័ន្ធ៥.៥ ៖ លិខិតអញ្ជើញអវត្តមាន ១0 ថ្ងៃ ) |
| | **៨. ចូលរួមកិច្ចប្រជុំប្រចាំខែ** ៖ ចូលរួមកិច្ចប្រជុំប្រចាំខែដែលដឹកនាំដោយនាយកសាលា ស្តីពីការគ្រប់គ្រង និងដំណើរការប្រព័ន្ធរម្លឹកជាមុន។ | - ទម្រង់/សៀវភៅគ្រប់គ្រងករណី និងតារាងគ្រប់គ្រងឥរិយាបថ<br>**ឧបសម្ព័ន្ធ៥.៣** ទម្រង់គ្រប់គ្រងករណី **ឧបសម្ព័ន្ធ៥.៤** តារាងគ្រប់គ្រងឥរិយាបថ **ឧបសម្ព័ន្ធ៥.៦** ទម្រង់កិច្ចសន្យាចូលរួម |
| | **៩. គ្រប់គ្រងករណីរបស់សិស្សបោះបង់ការសិក្សា** ៖ គ្រប់គ្រងករណីរបស់សិស្សបោះបង់ការសិក្សា ក្នុងថ្នាក់ តាមរយៈការស្វែងរកជំនួយពីអ្នកពាក់ព័ន្ធដើម្បីជួយឱ្យកុមារចូលរៀនវិញ។ | |
| ៣.១.២ គ្រូមុខវិជ្ជា | **១. កំណត់អត្តសញ្ញាណសិស្សរៀនយឺត** ៖ កំណត់អត្តសញ្ញាណសិស្សរៀនយឺតតាមមុខវិជ្ជា រួចជូនដំណឹងដល់គ្រូបន្ទុកថ្នាក់ ដើម្បីកំណត់លក្ខណវិនិច្ឆ័យរបស់សិស្ស ដែលងាយប្រឈមនឹងការបោះបង់ការសិក្សា។ផ្តោតលើសិស្សដែលរៀនយឺតភាសាខ្មែរ និងផ្តល់ការយកចិត្តទុកដាក់បន្ថែម និងផ្តោតអាទិភាពលើសកម្មភាពជំនួយបន្ថែម។ | - បញ្ជីឈ្មោះសិស្សរៀនយឺតក្នុងថ្នាក់ឬការស្នើឱ្យគ្រូយកចិត្តទុកដាក់ជាពិសេសលើសិស្សទាំងនោះ |

| អ្នកទទួលខុសត្រូវ | សកម្មភាព | ឯកសារ |
|---|---|---|
| | **២. យកចិត្តទុកដាក់ជាពិសេស លើសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា ៖** យកចិត្តទុកដាក់លើសិស្ស ដែលងាយប្រឈមនឹងការបោះបង់ការសិក្សាក្នុងពេលបង្រៀន និងខិតខំសួរសំណួរ ឬដាក់កិច្ចការផ្ទះជាប្រចាំសមស្របទៅតាមសមត្ថភាពរបស់ពួកគេ( សិស្សរៀនយឺត និងសិស្សរៀនលឿន ) និងផ្តល់ការបង្រៀនបន្ថែម។ | |
| | **៣. ដាក់សិស្សរៀនយឺត ឱ្យអង្គុយជាមួយសិស្សរៀនលឿន ៖** លើកទឹកចិត្តឱ្យសិស្ស ដែលងាយប្រឈមនឹងការបោះបង់ការសិក្សា ចាប់ដៃគូជាមួយសិស្សពូកែ ដើម្បីឱ្យសិស្សរៀនយឺតរៀនសូត្រពីសិស្សពូកែ។ | |
| ៣.១.៣ នាយក/ នាយករង បច្ចេកទេស | **១. ប្រមូលនិងវិភាគទិន្នន័យស្តីពីសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា ៖** ប្រមូលទិន្នន័យស្តីពីសិស្សដែលមានបញ្ហានៅដើមឆ្នាំសិក្សា រួចរៀងរាល់ខែ ត្រីមាស ឆមាស និងឆ្នាំ និងវិភាគពីផលប៉ះពាល់នៃបញ្ហារបស់សិស្ស និងរៀបចំរបាយការណ៍សង្ខេបស្តីពីសិស្សដែលមានបញ្ហាក្នុងត្រីមាស ឆមាសនិងឆ្នាំដើម្បីដាក់ជូនការិយាល័យអយកនិងអ្នកពាក់ព័ន្ធ។ | - សៀវភៅណែនាំនេះ ជាពិសេស ផ្នែកទី ២ ៖ ការរៀបចំប្រព័ន្ធរម្លឹកជាមុន |
| | **២. ការតម្រង់ទិសពីកម្មវិធីប្រព័ន្ធរម្លឹកជាមុន ៖** រៀបចំការតម្រង់ទិសអំពីកម្មវិធីប្រព័ន្ធរម្លឹកជាមុននៅអំឡុងកិច្ចប្រជុំគណៈកម្មការទប់ស្កាត់ការបោះបង់ការសិក្សា រួចកំណត់កិច្ចការ និងការទទួលខុសត្រូវសម្រាប់អ្នកពាក់ព័ន្ធ ដូចជា គ្រូបន្ទុកថ្នាក់ អ្នកណែនាំ គណៈកម្មការទ្រទ្រង់សាលារៀន ទីប្រឹក្សាកុមារី ទីប្រឹក្សាអាជីព និងក្រុមប្រឹក្សាស្ត្រី និងកុមារ។<br><br>ករណីសិក្សានៅក្នុងឧបសម្ព័ន្ធ៥.៨ អាចប្រើសម្រាប់ហ្វឹកហ្វឺនដល់គ្រូ និងអ្នកពាក់ព័ន្ធដែលអនុវត្តក្នុងការដោះស្រាយបញ្ហាដែលពួកគាត់អាចជួបប្រទះពេលសិស្សរបស់គាត់អវត្តមាន។ ករណីសិក្សាអាចសមស្របសម្រាប់ប្រើជាមួយក្រុមប្រឹក្សាកុមារ និងសហគមន៍ ហើយអាចប្តូរទៅជាការសម្តែងតួ ដើម្បីសម្តែងនៅក្នុងពិធីទិវាជាតិ។ | - តារាងកិច្ចការ និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ<br>- **ឧបសម្ព័ន្ធ៥.៨** ករណីសិក្សាស្តីពីសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា |
| | **៣.កិច្ចប្រជុំគ្រប់គ្រងករណី ៖** ដឹកនាំ ឬណែនាំការរៀបចំការគ្រប់គ្រងករណីរបស់សិស្សដែលបោះបង់ការសិក្សាក្នុងសហគមន៍ ដោយមានការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀន នាយករងបច្ចេកទេស មេឃុំ មេភូមិ និងគ្រូបន្ទុកថ្នាក់ពាក់ព័ន្ធ។ | - របៀបវារៈសម្រាប់កិច្ចប្រជុំគ្រប់គ្រងករណី |

| អ្នកទទួលខុសត្រូវ | សកម្មភាព | ឯកសារ |
|---|---|---|
| | **៤. កិច្ចប្រជុំប្រចាំខែ ៖** ដឹកនាំកិច្ចប្រជុំប្រចាំខែស្តីពីការគ្រប់គ្រង និងដំណើរការប្រព័ន្ធរម្លឹកជាមុន និងពិនិត្យឡើងវិញលើវឌ្ឍនភាពសកម្មភាពបន្ថែម ដែលបានកំណត់ ដើម្បីជួយដល់សិស្សដែលមានការលំបាកក្នុងការសិក្សា ដោយមានការចូលរួមពីនាយករងបច្ចេកទេស គ្រូបន្ទុកថ្នាក់ គណៈកម្មការទ្រទ្រង់សាលារៀន និងក្រុមប្រឹក្សាស្ត្រី និងកុមារ ដោយមានរបៀបវារៈច្បាស់លាស់។ គួរអញ្ជើញឱ្យបុគ្គលិកផ្សេងទៀតចូលរួមទៅតាមភាពពាក់ព័ន្ធ។ ពួកគេគួរពិចារណាថាតើពួកគេបានផ្តល់ជំនួយគ្រប់គ្រាន់ដល់ការទប់ស្កាត់សិស្ស ដែលងាយប្រឈមនឹងការបោះបង់ការសិក្សាឬទេ និងរាយការណ៍ពីសិស្សដែលអវត្តមានលើស ៦ដង/ខែ។ សម្រាប់សិស្សដែលគួរឱ្យព្រួយបារម្ភ ជាពិសេសសិស្សដែលអវត្តមានលើស ១០ដង/ខែ ឬសិស្ស ដែលមានការប្រែប្រួលឥរិយាបថគួរឱ្យព្រួយបារម្ភ គួររៀបចំកិច្ចប្រជុំករណីជាមួយសិស្ស មាតាបិតា និងគ្រូបន្ទុកថ្នាក់ និង/ឬនាយកសាលា។ | - របៀបវារៈសម្រាប់កិច្ចប្រជុំប្រចាំខែ និងកំណត់សម្គាល់ និងចំណុចសកម្មភាពពីកិច្ចប្រជុំមុនៗ។ |
| | **៥. ក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការនារី និងកុមារ ៖** ទាក់ទងជាមួយក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការនារី និងកុមារដើម្បីរៀបចំការចុះតាមផ្ទះសិស្សដែលអវត្តមាន ប្រសិនបើមិនអាចទាក់ទងទៅមាតាបិតា ឬក៏ពួកគេរស់នៅឆ្ងាយពីសាលា ព្រោះក្រុមប្រឹក្សាឃុំអាចមានថវិកាលើសោហ៊ុយសាំង សម្រាប់គោលបំណងនេះ។ | - ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន<br>- ទិន្នន័យស្តីពីការបោះបង់ការសិក្សា មូលហេតុនៃការបោះបង់ការសិក្សា/ការចុះឈ្មោះចូលរៀនតិច |
| | **៦.ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំដើម្បីទប់ស្កាត់ការបោះបង់ការសិក្សា ៖** ពិនិត្យឡើងវិញ និងជួយដល់គ្រូបន្ទុកថ្នាក់ក្នុងការកំណត់អត្តសញ្ញាណសិស្ស ដែលងាយប្រឈមនឹងការបោះបង់ការសិក្សា និងតម្រូវការរបស់ពួកគេក្នុងការរៀបចំផែនការប្រតិបត្តិការប្រចាំឆ្នាំ និងចាត់វិធានកាជាក់លាក់ដើម្បីជួយដល់សិស្សទាំងនោះ និងដាក់បញ្ចូលពួកគេក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ។ | |
| | **៧. បង្កើនការយល់ដឹងពីការទប់ស្កាត់ការបោះបង់ការសិក្សាក្នុងសហគមន៍ ៖** ធានាថា មានការផ្សព្វផ្សាយជាប្រចាំដល់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសមាតាបិតា និងអាណាព្យាបាល និងសិស្សទាំងអស់ និងសមាជិកសហគមន៍ផ្សេងទៀត ស្តីពីច្បាប់សំខាន់ៗនៅកម្ពុជាដែលពាក់ព័ន្ធនឹងពលកម្មកុមារនិងសិទ្ធិទទួលបានការអប់រំមូលដ្ឋាន អត្ថប្រយោជន៍នៃការអប់រំ និងរបៀបដែលការអប់រំជួយទប់ស្កាត់ការបោះបង់ការសិក្សានៅកម្រិតគ្រួសារ។ | - ផ្នែក ២.៦ ៖ ការបង្កើនការយល់ដឹង និងការតស៊ូមតិក្នុងសហគមន៍ |

| អ្នកទទួលខុសត្រូវ | សកម្មភាព | ឯកសារ |
| --- | --- | --- |
| ៣.១.៤ ប្រធាន/អនុប្រធានថ្នាក់ | **១. ជួយដល់ការកំណត់អត្តសញ្ញាណសិស្សអវត្តមាន ៖** ផ្តល់ជំនួយដល់គ្រូបន្ទុកថ្នាក់ក្នុងការកំណត់អត្តសញ្ញាណសិស្សដែលប្រឈមនឹងការបោះបង់ការសិក្សាតាមរយៈការរៀបចំបញ្ជីឈ្មោះសិស្សក្នុងថ្នាក់ និងការកត់ត្រាអវត្តមានសិស្ស។ | - បញ្ជីឈ្មោះសិស្សដែលត្រូវបានកំណត់អត្តសញ្ញាណថាងាយប្រឈមនឹងការបោះបង់ការសិក្សា<br>- សៀវភៅសម្រង់អវត្តមាន<br>- តារាងស្រង់ពិន្ទុ (តាមមុខវិជ្ជានៅមធ្យមសិក្សា) |
| | **២.រាយការណ៍ពីសិស្សដែលអវត្តមាន៣ដងឡើងទៅ/សប្តាហ៍៖** រាយការណ៍ទៅគ្រូបន្ទុកថ្នាក់ យ៉ាងហោចណាស់រាល់សប្តាហ៍អំពីសិស្សដែលអវត្តមាន៣ដងឡើងទៅ/សប្តាហ៍លើស៦ដង/ខែនិងប្រសិនបើសិស្សអវត្តមានលើស ១០ដង។ | |
| | **៣ជួយដល់សិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា៖** ស្វែងយល់ពីស្ថានភាពរបស់សិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា និងផ្តល់ជំនួយប្រសិនបើពួកគេមានអារម្មណ៍ក្រៀមក្រំ ឬប្រាប់ប្រធានថ្នាក់ពីបញ្ហារបស់ខ្លួន។ ចែករំលែកបញ្ហាប្រឈមរបស់សិស្សទាំងនេះជាមួយគ្រូបន្ទុកថ្នាក់។ | |
| | **៤.ពិភាក្សាជាមួយមិត្តរួមថ្នាក់ស្តីពីរបៀបជួយគ្នាទៅវិញទៅមក៖** ពិភាក្សាជាមួយមិត្តរួមថ្នាក់ពីរបៀបជួយគ្នាទៅវិញទៅមកលើបញ្ហានានា ឬការសិក្សា និងស្វែងរកដំណោះស្រាយ និងលទ្ធភាពដែលពួកគេអាចជួយដោយផ្ទាល់ ឬស្នើសុំទៅគណៈកម្មការទប់ស្កាត់សិស្សបោះបង់ការសិក្សា។ | |
| ៣.១.៥ ក្រុមប្រឹក្សាកុមារ | **១.ការគូសផែនទីខ្នងផ្ទះ ឬផែនទីសិក្សា ៖** ចូលរួមជាមួយអាជ្ញាធរភូមិ ឃុំដើម្បីគូសផែនទីខ្នងផ្ទះរបស់សិស្ស ដែលប្រឈមនឹងការបោះបង់ការសិក្សាដើម្បីរៀបចំសកម្មភាពគាំទ្រ។t | |
| | **២. ជួយកំណត់រកការគាំទ្រដល់សិស្សរៀនយឺត ៖** ជួយកំណត់អត្តសញ្ញាណសិស្ស ដែលមានសមត្ថភាព និង លទ្ធភាពដើម្បីជួយដល់សិស្សរៀនយឺត និងទប់ស្កាត់ការបោះបង់ការសិក្សា។ លើកទឹកចិត្តមិត្តភក្តិឱ្យខិតខំរៀនសូត្រ និងមិនរើសអើងសិស្សដែលមានជីវភាពលំបាក ឬកម្រិតសិក្សាខុសគ្នា។ | |

| អ្នកទទួលខុសត្រូវ | សកម្មភាព | ឯកសារ |
|---|---|---|
| | **៣. កិច្ចប្រជុំក្រុមប្រឹក្សាសិស្ស ៖** ពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសិស្ស ស្ដីពីសកម្មភាពជួយទប់ស្កាត់ការបោះបង់ការសិក្សា ជាពិសេសសកម្មភាពដែលអាចធ្វើឡើងដោយខ្លួនឯង ឬធ្វើឡើងដោយមានជំនួយពីគ្រូ ឬបុគ្គលិកអប់រំ (ក្លឹបសិក្សា ការគាំទ្រអំណានបន្ថែម ការរៃអង្គាសមូលនិធិ ដើម្បីជួយដល់សិស្សក្រីក្រ សកម្មភាពកីឡា ការរក្សាបរិស្ថានស្អាត និងអនាម័យ ការលើកឡើងពីតម្រូវការរបស់សិស្ស ដោយរាយការណ៍ពីឧប្បត្តិហេតុក្នុងសាលា ឬការលំបាករបស់សិស្សទៅគ្រូបន្ទុកថ្នាក់ ឬនាយកសាលា)។ | - របៀបវារៈ និងកំណត់សម្គាល់របស់ក្រុមប្រឹក្សាកុមារដូចជាចំណុចសកម្មភាពពីកិច្ចប្រជុំមុនៗ |
| | **៤. ផ្សព្វផ្សាយពីអត្ថប្រយោជន៍នៃការអប់រំ និងសិទ្ធិទទួលបានការអប់រំមូលដ្ឋាន៖** ផ្សព្វផ្សាយដល់សិស្សគ្រប់រូបពីច្បាប់សំខាន់ៗនៅកម្ពុជា ដែលពាក់ព័ន្ធនឹងពលកម្មកុមារ និងសិទ្ធិទទួលបានការអប់រំមូលដ្ឋាន អត្ថប្រយោជន៍នៃការអប់រំ និងរបៀបដែលការអប់រំជួយទប់ស្កាត់ការបោះបង់ការសិក្សា នៅកម្រិតគ្រួសារ និងចូលរួមក្នុងយុទ្ធនាការសាលារៀន និងជួយរៀបចំដាកពាក្យស្លោក។ល។ ជាមួយសិស្សផ្សេងទៀត។ អញ្ជើញឱ្យសិស្សដែលជោគជ័យ ផ្ដល់បទពិសោធន៍ដើម្បីលើកទឹកចិត្តសិស្សបច្ចុប្បន្ន ឱ្យខិតខំប្រឹងប្រែងរៀនសូត្រ។ | - ផ្នែក ២.៦ ៖ ការបង្កើនការយល់ដឹង និងការតស៊ូមតិក្នុងសហគមន៍ |
| | **៥. តាមដានសិស្សអវត្តមាន ៖** ជួយតាមដានសិស្សដែលអវត្តមាន។ | |
| ៣.១.៦ គណៈកម្មការទ្រទ្រង់សាលារៀន | **១. កាគូរផែនទីខ្នងផ្ទះ ឬផែនទីស ៖** សហការជាមួយនាយកសាលា គ្រូបន្ទុកថ្នាក់ ក្រុមប្រឹក្សាស្ត្រី និងកុមារ និងមេភូមិដើម្បីគូសផែនការខ្នងផ្ទះសិស្ស ដែលងាយប្រឈមនឹងការបោះបង់ការសិក្សា ដើម្បីរៀបចំសកម្មភាពគាំទ្រពួកគេ។ | - ស្ថិតិកុមារគ្រប់វ័យសិក្សា |
| | **២.តាមដានសិស្សអវត្តមាន ៖** សហការជាមួយនាយកសាលា និងគ្រូដើម្បីចុះទៅផ្ទះរបស់សិស្សដែលបោះបង់ការសិក្សា រួចរាយការណ៍ទៅនាយកសាលាសម្រាប់ការរៀបចំផែនការបន្ត។ ចូលរួមកិច្ចប្រជុំ ក្នុងករណីមានសិស្សបោះបង់ការសិក្សានៅសហគមន៍ ព្រមទាំងជំរុញឱ្យគ្រូ និងសិស្សជួយបំផុសឱ្យកុមារបញ្ចប់យ៉ាងហោចណាស់ការអប់រំមូលដ្ឋាន។ | - បញ្ជីហៅឈ្មោះសិស្ស |

| អ្នកទទួលខុសត្រូវ | សកម្មភាព | ឯកសារ |
|---|---|---|
| | **៣. ជួយស្វែងរកកន្លែងសុវត្ថិភាពសម្រាប់បង្កើតក្លឹបសិក្សាក្នុងសហគមន៍៖** ជួយរៀបចំកន្លែងសុវត្ថិភាពសម្រាប់បង្កើតក្លឹបសិក្សាតាមភូមិ ជាពិសេសសម្រាប់សិស្សដែលខ្សោយអំណានភាសាខ្មែរ និងធ្វើកិច្ចការដែលគ្រូដាក់ឱ្យសិស្សធ្វើនៅផ្ទះប៉ុន្តែពូកែមុខវិជ្ជាផ្សេង។ | - កិច្ចការផ្ទះ និងលំហាត់ផ្សេងៗ |
| | **៤. ផ្សព្វផ្សាយពីអត្ថប្រយោជន៍នៃការអប់រំ និងសិទ្ធិទទួលបានការអប់រំមូលដ្ឋាន៖** ជួយដល់ការផ្សព្វផ្សាយដល់មាតាបិតាឬអ្នកអាណាព្យាបាលសិស្សគ្រប់រូប អំពីច្បាប់សំខាន់ៗនៅកម្ពុជាដែលពាក់ព័ន្ធនឹងពលកម្មកុមារ និងសិទ្ធិទទួលបានការអប់រំមូលដ្ឋាន អត្ថប្រយោជន៍នៃការអប់រំ និងរបៀបដែលការអប់រំ ជួយទប់ស្កាត់ការបោះបង់ការសិក្សានៅកម្រិតគ្រួសារ។ | - ផ្នែក ២.៦ ៖ ការបង្កើនការយល់ដឹង និងការតស៊ូមតិក្នុងសហគមន៍ |
| | **៥. កៀរគរមូលនិធិ៖** កៀរគរមូលនិធិជួយដល់សិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា ដូចជា ការផ្តល់អាហារូបករណ៍ មធ្យោបាយធ្វើដំណើរ។ | |
| ៣.១.៧ អាជ្ញាធរមូលដ្ឋាន | **១. ការតម្រង់ទិសពីកម្មវិធីប្រព័ន្ធរម្លឹកជាមុន៖** ចូលរួមការតម្រង់ទិសពីកម្មវិធីប្រព័ន្ធរម្លឹកជាមុន ដោយកំណត់កិច្ចការ និងការទទួលខុសត្រូវសម្រាប់អ្នកពាក់ព័ន្ធ ដូចជា ស្ត្រី និងកុមារបង្គោលក្នុងឃុំ មេភូមិ មាតាបិតាសិស្ស គណៈកម្មការទ្រទ្រង់សាលារៀន គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារ( គកនក ) ដោយមានការចូលរួមពីនាយកសាលា។ | - ផ្នែក ២.៦ ៖ ការបង្កើនការយល់ដឹង និងការតស៊ូមតិក្នុងសហគមន៍ |
| | **២. បង្កើនការយល់ដឹងពីអត្ថប្រយោជន៍នៃការអប់រំ និងសិទ្ធិទទួលបានការអប់រំ ៖** ជួយដល់នាយកសាលា គ្រូបង្រៀន និងគណៈកម្មការទ្រទ្រង់សាលាក្នុងការរៀបចំសកម្មភាពក្នុងសហគមន៍ និងចូលរួមក្នុងសកម្មភាពទាំងនោះ។ | |
| | **៣. កៀរគរមូលនិធិ ៖** កៀរគរមូលនិធិជួយដល់សិស្សដែលប្រឈមនឹងការបោះបង់ការសិក្សា ដូចជា ការផ្តល់អាហារូបករណ៍ មធ្យោបាយធ្វើដំណើរជាដើម។ | |
| | **៤. ធានាសុវត្ថិភាពសិស្សដែលធ្វើដំណើរទៅរៀន ៖** ជួយដល់សាលា ក្នុងការធានាធ្វើយ៉ាងណាឱ្យសិស្សអាចទៅដល់សាលាដោយសុវត្ថិភាព។ | |

## ៣.២ តួនាទីរបស់ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក /ការិយាល័យ អប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ

### ៣.២.១ ផ្តោតអាទិភាពលើការបង្កើត និងការកសាងសមត្ថភាពប្រព័ន្ធរម្លឹកជាមុនក្នុងពេលពិនិត្យតាមដាន

ក្នុងពេលវាយតម្លៃសាលាកុមារមេត្រីក្នុងក្រុង /ស្រុក/ខណ្ឌ ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក/ការិយាល័យអប់រំ យុវជន និងកីឡាក្រុង /ស្រុក/ខណ្ឌ គួរជំរុញឱ្យសាលារៀនផ្តោតអាទិភាពលើការបង្កើត និងដំណើរការប្រព័ន្ធរម្លឹកជាមុននៅគ្រប់សាលា និងធានាថា សាលារៀនបានអនុវត្តសកម្មភាពទប់ស្កាត់ការបោះបង់ការសិក្សា និងលើកទឹកចិត្តឱ្យសិស្សគ្រប់រូបបញ្ចប់ការអប់រំមូលដ្ឋាន។ ជាពិសេស ធ្វើយ៉ាងណាឱ្យសាលារៀន ៖

- មានឯកសារចម្លងសៀវភៅណែនាំនេះ
- បង្កើតគណៈកម្មការទទួលខុសត្រូវលើការទប់ស្កាត់សិស្ស ដែលងាយប្រឈមនឹងការបោះបង់ការសិក្សា
- ត្រួតពិនិត្យសាលារៀន ដែលមានសិស្សងាយប្រឈមនឹងការបោះបង់ការសិក្សាដើម្បីធានាការអនុវត្តប្រព័ន្ធរម្លឹកជាមុន
- ដាក់បញ្ចូលក្នុងរបាយការណ៍នូវការពិនិត្យតាមដានសិស្ស ដែលបោះបង់ការសិក្សានៅតាមសាលានីមួយៗ និងការណែនាំនានាដើម្បីធានាការអនុវត្តប្រព័ន្ធរម្លឹកជាមុន
- ណែនាំសាលារៀនពីអន្តរាគមន៍បន្ថែមដែលអាចអនុវត្តបាន ក្នុងការទប់ស្កាត់ការបោះបង់ការសិក្សាក្នុងតំបន់
- ការបណ្តុះបណ្តាលសមត្ថភាព និងចែករំលែកការអនុវត្តល្អក្នុងពេលចុះពិនិត្យតាមដាន។

### ៣.២.២ គ្រប់គ្រងទិន្នន័យសិស្ស

ប្រមូលទិន្នន័យសិស្សក្នុងស្រុកដែលមានបញ្ហានៅដើមឆ្នាំសិក្សា និងរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំ រួចកំណត់អត្តសញ្ញាណ និងវិភាគបញ្ហាប្រឈមរបស់សិស្ស និងផលប៉ះពាល់នៃអន្តរាគមន៍នានាដើម្បីជួយដល់ពួកគេ រួចបញ្ជូនទៅគណៈអភិបាលក្រុង/ស្រុក/ខណ្ឌ មន្ទីរ និងក្រសួង អប់រំ យុវជន និងកីឡា។

### ៣.២.៣ ការវិភាគផែនការប្រតិបត្តិប្រចាំឆ្នាំ

ការិយាល័យអប់រំ យុវជន និងកីឡា គួរពិនិត្យឡើងវិញលើផែនការប្រតិបត្តិប្រចាំឆ្នាំ ដើម្បីធានាថាសាលារៀនបានដាក់បញ្ចូលអន្តរាគមន៍ទប់ស្កាត់ការបោះបង់ការសិក្សា និងផ្តល់ជំនួយដល់សាលាដែលមិនសូវយកចិត្តទុកដាក់លើការបោះបង់ការសិក្សា ដើម្បីកែលម្អផែនការ។

## ៣.៣ តួនាទីរបស់មន្ទីរអប់រំ យុវជន និងកីឡា

### ៣.៣.១ ការវិភាគទិន្នន័យស្តីពីការទប់ស្កាត់ការបោះបង់ការសិក្សា

មន្ទីរអប់រំយុវជននិងកីឡាគួរវិភាគទិន្នន័យដែលទទួលបានដើម្បីវាយតម្លៃសាលាដែលមានការលំបាកបំផុតក្នុងការដោះស្រាយបញ្ហាបោះបង់ការសិក្សា និងអវត្តមានសិស្ស និងកំណត់យកសាលាទាំងនេះក្នុងការកសាងសមត្ថភាព។

### ៣.៣.២ ការវិភាគផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន

មន្ទីរអប់រំ យុវជន និងកីឡា គួរពិនិត្យឡើងវិញលើផែនការប្រតិបត្តិការប្រចាំឆ្នាំដើម្បីធានាថា សាលាបានរួមបញ្ចូលអន្តរាគមន៍ទប់ស្កាត់ការបោះបង់ការសិក្សា។

### ៣.៣.៣ ការកសាងសមត្ថភាព

ធានាថា សាលាទាំងអស់ទទួលបានសៀវភៅណែនាំនេះ និងការតម្រង់ទិសដោយសង្ខេបស្តីពីសៀវភៅណែនាំនេះក្នុងកិច្ចប្រជុំនាយកសាលាប្រចាំខែ។

បង្កើនសមត្ថភាពរបស់បុគ្គលិកសាលា  ក្នុងការដោះស្រាយតម្រូវការរបស់សិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា  តាមរយៈការផ្តល់ការបង្វឹកបង្ហាត់  និងការកំណត់រកការអនុវត្តល្អក្នុងខេត្ត។ សាលាដែលអនុវត្តបានល្អគួរត្រូវបានលើកទឹកចិត្តឱ្យធ្វើបទបង្ហាញដល់សាលាផ្សេងទៀតក្នុងខេត្ត។

### ៣.៣.៤ ផែនការថ្នាក់ខេត្តសម្រាប់ការឆ្លើយតបនឹងសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា

រៀបចំរបាយការណ៍នៅដំណាច់ឆមាសដាក់ជូនក្រសួងអប់រំ យុវជន និងកីឡាដើម្បីរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តប្រព័ន្ធរម្លឹកជាមុន និងអន្តរាគមន៍ដែលជួយកាត់បន្ថយការបោះបង់ការសិក្សា និងបង្កើនវត្តមានសិស្ស។

# ៤. អន្តរាគមន៍ទប់ស្កាត់សិស្សបោះបង់ការសិក្សា

## ៤.១ សកម្មភាពឆ្លើយតបបឋម

សកម្មភាពឆ្លើយតបបឋមត្រូវបានធ្វើឡើងនៅពេលគ្រូបន្ទុកថ្នាក់ (ដោយមានជំនួយពីប្រធានថ្នាក់) កំណត់ឃើញថាអាចមានសិស្សដែលមានបញ្ហា។ អន្តរាគមន៍ឆ្លើយតបបឋមមានគោលបំណងធានាថា រាល់ព័ត៌មានពាក់ព័ន្ធស្តីពីបញ្ហារបស់សិស្សត្រូវបានវាយតម្លៃ ហើយសិស្សទទួលបានជំនួយសមស្របទៅតាមតម្រូវការដើម្បីធ្វើយ៉ាងណាមិនឱ្យសិស្សរៀនមិនទាន់គេ និងប្រឈមនឹងការបោះបង់ការសិក្សា។ ត្រូវអនុវត្តសកម្មភាពឆ្លើយតបបឋមឱ្យបានទាន់ពេលវេលា ដើម្បីកំណត់អត្តសញ្ញាណសិស្សដែលមានបញ្ហាឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ គេរំពឹងថា សកម្មភាពទាំងនេះគ្រាន់តែជាការឆ្លើយតបបឋមប៉ុណ្ណោះ និងប្រហែលជាត្រូវតាមដានសិស្សជាច្រើន និងផ្តល់ជំនួយបន្ថែមប្រសិនបើសាលាចង់ទប់ស្កាត់មិនឱ្យមានសិស្សបោះបង់ការសិក្សា។

ការតាមដានអវត្តមានសិស្សត្រូវមានភាពហ្មត់ចត់ ព្រោះអវត្តមានជាប្រចាំធ្វើឱ្យសិស្សរៀនមិនទាន់គេ ហើយសិស្សអាចបោះបង់ការសិក្សានៅពេលក្រោយ។ ដ្យាក្រាមខាងក្រោមសង្ខេបពីប្រព័ន្ធរាយការណ៍ និងប្រព័ន្ធឆ្លើយតបបឋម អាស្រ័យលើថាតើសិស្សធ្លាប់ត្រូវបានកំណត់អត្តសញ្ញាណថា "ងាយប្រឈមនឹងការបោះបង់ការសិក្សា" ឬទេ ៖

តារាងខាងក្រោមរៀបរាប់លម្អិតពីសកម្មភាពឆ្លើយតបបឋមដែលគួរធ្វើឡើង ទៅតាមបញ្ហាដែលកំណត់បានដំបូង។

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អន្តរាគមន៍ដែលស្នើឡើង |
|---|---|---|---|
| ៤.១.១ | សិស្សអវត្តមាន ៣ ដងឡើងទៅ/សប្តាហ៍ ឬ ៦ ដង ឡើងទៅ/ខែ | **តាមដានយ៉ាងរហ័សលើសិស្សដែលអវត្តមានទាំងអស់ និងទាក់ទងទៅមាតាបិតារបស់សិស្សដែលធ្លាប់ត្រូវបានកំណត់អត្តសញ្ញាណថា "ងាយប្រឈមនឹងការបោះបង់ការសិក្សា"** | |
| | | 1. សួរសិស្សផ្សេងទៀត ថាតើពួកគេដឹងពីហេតុផលដែលសិស្សនោះអវត្តមាន និងថាតើមាតាបិតារបស់សិស្សនោះបានធ្វើលិខិតសុំច្បាប់ឬទេ និងត្រូវទទួលបានព័ត៌មានស្តីពីស្ថានភាពរបស់សិស្ស។ | មិត្តរួមថ្នាក់/ក្រុមប្រឹក្សាកុមារ |
| | | 2. សម្រាប់សិស្ស ដែលមិនត្រូវបានកំណត់អត្តសញ្ញាណថាងាយប្រឈមនឹងការបោះបង់ការសិក្សា គួរពិនិត្យថា សិស្សនោះគ្មានបញ្ហាធំដុំជាមួយមិត្តភក្តិ។ ប៉ុន្តែប្រសិនបើសិស្សនោះអវត្តមាន៦ដងឬច្រើនជាង ៦ ដង/ខែ សិស្សនោះនឹងក្លាយជាសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា ហើយគ្រូគួរទាក់ទងទៅមាតាបិតា។ | គ្រូបន្ទុកថ្នាក់ |

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អន្តរាគមន៍ដែលស្នើឡើង |
|---|---|---|---|
| | | 3. សម្រាប់សិស្សដែលត្រូវបានកំណត់អត្តសញ្ញាណថាងាយប្រឈមនឹងការបោះបង់ការសិក្សា គ្រូត្រូវទាក់ទងទៅមាតាបិតា (ឬប្រធានសហគមន៍ក្នុងមូលដ្ឋាន) ដើម្បីស្វែងយល់ពីបញ្ហា និងជំរុញឱ្យពួកគេបញ្ជូនសិស្សនោះឱ្យចូលរៀនវិញ ឬរៀបចំដាក់កិច្ចការសាលាមួយចំនួន ប្រសិនបើសិស្សនោះត្រូវអវត្តមានមួយរយៈប៉ុន្តែនៅអាចសិក្សាបាន (ឧ. ក្រោយកើតមានគ្រោះថ្នាក់)[4]។ | គ្រូបន្ទុកថ្នាក់/គ្រូមុខវិជ្ជា សិស្សផ្សេងទៀត សហគមន៍ |
| | | 4. និយាយជាមួយសិស្សឱ្យត្រឡប់មករៀនវិញដើម្បីឱ្យដឹងថា ពួកគេអាចធ្វើបាន ឬទេ និងថាតើពួកគេមានបញ្ហា ឬការលំបាកអ្វីដែរឬទេ។ គ្រូមុខវិជ្ជាត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើសិស្សនោះ នៅពេលពួកគេចូលរៀនវិញ និងធ្វើយ៉ាងណាឱ្យពួកគេរៀនទាន់សិស្សផ្សេងទៀត។ | គ្រូបន្ទុកថ្នាក់/គ្រូមុខវិជ្ជា |
| ៤.១.២ | សិស្សដែលអវត្តមាន ១០ ដងឡើងទៅ/ខែ | **ជួបជាមួយមាតាបិតារបស់សិស្សដែលអវត្តមាន ១០ ដងឡើងទៅ/ខែ** | |
| | | 1. សួរសិស្សផ្សេងទៀត ថាតើពួកគេដឹងពីហេតុផលដែលសិស្សនោះអវត្តមាន និងថាតើមាតាបិតារបស់សិស្សនោះបានផ្ញើលិខិតសុំច្បាប់ឬទេ និងត្រូវទទួលបានព័ត៌មានស្តីពីស្ថានភាពរបស់សិស្ស។ | មិត្តរួមថ្នាក់/ក្រុមប្រឹក្សាកុមារ |
| | | 2. គ្រូបន្ទុកថ្នាក់គួរពិភាក្សាបញ្ហានោះជាមួយនាយកសាលា និងបុគ្គលិកផ្សេងទៀត និងសម្រេចយកអ្នកដែលត្រូវរៀបចំកិច្ចប្រជុំជាមួយមាតាបិតា និងសិស្ស។ សាលាគួរទាក់ទងទៅមាតាបិតា និងរៀបចំឱ្យពួកគាត់មកសាលា ឬរៀបចំការចុះដល់ផ្ទះ។ គួរមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ឬមានកំណត់ត្រា និងកំណត់ហេតុកិច្ចប្រជុំ ៖<br>- ស្តាប់ពីការលំបាករបស់សិស្ស/គ្រួសារ<br>- ស្វែងយល់ពីស្ថានភាពជាក់ស្តែងរបស់សិស្ស និងគ្រួសាររបស់សិស្ស<br>- ព្យាយាមធ្វើឱ្យប្រាកដថាយើងរកឃើញហេតុផលពិត ដោយមិនទទួលចម្លើយដំបូង សូមរកមូលហេតុពិតប្រាកដ និងច្បាស់លាស់បំផុត។ ពេលខ្លះមនុស្សយើងមានការខ្មាស់អៀនក្នុងការបង្ហាញបញ្ហាពិតប្រាកដ។ | គ្រូបន្ទុកថ្នាក់/គ្រូមុខវិជ្ជា/នាយកសាលា/សមាជិកសហគមន៍ |

4 សំខាន់បំផុតត្រូវដឹងពីស្ថានភាពគ្រួសារនៅពេលទាក់ទងទៅមាតាបិតា។ ពេលខ្លះ សិស្សអាចអវត្តមានដោយសារអំពើហិង្សាក្នុងគ្រួសារ។ ប្រសិនបើមានកង្វល់ណាមួយពាក់ព័ន្ធនឹងស្ថានភាពរបស់កុមារនៅផ្ទះ គួរចុះដល់ផ្ទះ ឬធ្វើអន្តរាគមន៍ផ្សេងទៀត។

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អន្តរាគមន៍ដែលស្នើឡើង |
|---|---|---|---|
| | | - ផ្ដល់ឱកាសឱ្យសិស្សជ្រើសរើស និងកែតម្រូវកំហុស<br>- យល់ច្បាស់ពីសារៈសំខាន់នៃការមករៀនជាប្រចាំសម្រាប់សិស្ស ដែលអាចរៀនសូត្រ និងបញ្ចប់ការសិក្សាបានសមស្រប<br>- រម្លឹកមាតាបិតាឱ្យបានដឹងច្បាប់ស្ដីពីពលកម្មកុមារ និងសិទ្ធិរបស់កុមារក្នុងការទទួលបានយ៉ាងហោចណាស់ការអប់រំមូលដ្ឋាន (ផ្នែក ២.៦) និងអត្ថប្រយោជន៍នៃការអប់រំ ក៏ដូចជាជួយដោះស្រាយបញ្ហាប្រកបដោយការគួរសម និងភាពបត់បែន។<br>- ឯកភាពជាមួយសិស្ស និងមាតាបិតា/អាណាព្យាបាល ពីសារៈសំខាន់នៃការសិក្សារបស់សិស្ស។ ចូរមើលឧបសម្ព័ន្ធ ៥.៦ ទម្រង់កិច្ចសន្យាចូលរួម | |
| | | 3. និយាយជាមួយសិស្សឱ្យត្រឡប់មករៀនវិញដើម្បីឱ្យដឹងថា ពួកគេអាចធ្វើបាន ឬទេ និងថាតើពួកគេមានបញ្ហា ឬការលំបាកអ្វីដែរ ឬទេ។ ធានាថា ពួកគេអាចធ្វើកិច្ចការ/លំហាត់ដែលខកខានមិនបានធ្វើ ហើយគ្រូមុខវិជ្ជាត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើសិស្សនោះ នៅពេលពួកគេចូលរៀនវិញ និងធ្វើយ៉ាងណាឱ្យពួកគេរៀនទាន់សិស្សផ្សេងទៀត។ | គ្រូបន្ទុកថ្នាក់/ គ្រូមុខវិជ្ជា/ សិស្សផ្សេងទៀត |
| ៤.១.៣ | សិស្សដែលមានពិន្ទុទាប | **យកចិត្តទុកដាក់បន្ថែមលើសិស្សដែលមានពិន្ទុទាប** | |
| | | 1. ជួបជាមួយសិស្ស ដើម្បីស្វែងយល់ថាតើពួកគេមានការលំបាក ឬបញ្ហានៅផ្ទះ ឬសាលា ឬទេ ឬបញ្ជូនពួកគេទៅទីប្រឹក្សាកុមារី ក្រុមប្រឹក្សាកុមារ ឬក្រុមប្រឹក្សាយុវជន។ ពិភាក្សាពីការលំបាករបស់សិស្ស និងឯកភាពលើចំណាត់ការជួយឱ្យពួកគេរៀនទាន់សិស្សផ្សេង ឬជួយដោះស្រាយបញ្ហានៅផ្ទះរបស់ពួកគេ។ ព្យាយាមធ្វើឱ្យប្រាកដថាយើងរកឃើញហេតុផលពិត ដោយមិនទទួលចម្លើយដំបូង សូមរកមូលហេតុពិតប្រាកដនិងច្បាស់លាស់បំផុត។ ពេលខ្លះមនុស្សយើងមានការខ្មាស់អៀនក្នុងការបង្ហាញបញ្ហាពិតប្រាកដ។ | គ្រូបន្ទុកថ្នាក់ |
| | | 2. យកចិត្តទុកដាក់បន្ថែមទៀតលើសិស្សក្នុងថ្នាក់ និងធ្វើយ៉ាងណាឱ្យពួកគេយល់ និងផ្ដល់ជំនួយបន្ថែម។ ដាក់សិស្សរៀនយឺតឱ្យអង្គុយជិតសិស្សពូកែ និងប្រាប់ពួកគេពីគ្លីបមុខវិជ្ជា ឬជំនួយពិសេសដល់សិស្សដែលរៀនរៀនយឺត។ ឱ្យគ្រូមុខវិជ្ជាយកចិត្តទុកដាក់លើសិស្សក្នុងថ្នាក់ ជាពិសេសមុខវិជ្ជាដែលពួកគេរៀនយឺតបំផុត។ | គ្រូបន្ទុកថ្នាក់/ គ្រូមុខវិជ្ជា |

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អន្តរាគមន៍ដែលស្នើឡើង |
|---|---|---|---|
| ៤.១.៤ | សិស្សដែលមានឥរិយាបថមិនល្អនៅក្នុង ឬក្រៅថ្នាក់ | ការកែតម្រូវឥរិយាបថមិនល្អទាំងក្នុង និងក្រៅថ្នាក់ | |
| | | 1. ជួបជាមួយសិស្ស ដើម្បីស្វែងយល់ថាតើពួកគេមានការលំបាក ឬបញ្ហានៅផ្ទះ ឬសាលា ឬទេ ឬបញ្ជូនពួកគេទៅទីប្រឹក្សាកុមារី ក្រុមប្រឹក្សាកុមារ ឬក្រុមប្រឹក្សាយុវជន។ ព្យាយាមធ្វើឱ្យប្រាកដថាយើងរកឃើញហេតុផលពិត ដោយមិនទទួលចម្លើយដំបូង សូមរកមូលហេតុពិតប្រាកដនិងច្បាស់លាស់បំផុត។ពេលខ្លះមនុស្សយើងមានការខ្មាស់អៀនក្នុងការបង្ហាញបញ្ហាពិតប្រាកដ។ ពិភាក្សាពីការលំបាករបស់សិស្ស និងឯកភាពលើចំណាត់ការជួយឱ្យពួកគេរៀនទាន់សិស្សផ្សេង ឬជួយដោះស្រាយបញ្ហានៅផ្ទះរបស់ពួកគេ។ ពិភាក្សាពីសារៈសំខាន់នៃការអប់រំជាមួយសិស្ស និងការធានាថា សិស្សបានផ្តោតលើការសិក្សាក្នុងថ្នាក់ និងមិនរំខានដល់សិស្សផ្សេងទៀត។ ឯកភាពជាមួយសិស្សពីឥរិយាបថសមស្របនៅក្នុង និងក្រៅថ្នាក់។ ប្រសិនបើសិស្សមានឥរិយាបថមិនល្អ សូមប្រាប់សិស្សនោះថា សាលានឹងទាក់ទងទៅមាតាបិតា ឬអាណាព្យាបាលរបស់គាត់ ដើម្បីពិភាក្សាពីស្ថានភាពនេះ ប្រសិនបើពួកគេមិនកែខ្លួន។ យកចិត្តទុកដាក់បន្ថែមលើសិស្សទាំងនោះក្នុងថ្នាក់ និងដាក់ពួកគេឱ្យអង្គុយនៅជិតតុមុខ។ លើកសរសើរឥរិយាបថល្អ។ | គ្រូបន្ទុកថ្នាក់ ឬនាយកសាលា |
| | | 2. ប្រសិនបើសិស្សនោះមិនកែខ្លួន គ្រូទទួលបន្ទុកថ្នាក់គួរពិភាក្សាជាមួយនាយកសាលា និងគ្រូគ្រប់មុខវិជ្ជាពាក់ព័ន្ធ រួចទូរស័ព្ទណាត់មាតាបិតាពិភាក្សាគ្នាដោះស្រាយស្ថានភាពនោះ។ នាយកសាលាត្រូវមានវត្តមានក្នុងកិច្ចប្រជុំនោះ។ គួរមានកំណត់ត្រា និងកំណត់ហេតុកិច្ចប្រជុំ ដោយពិភាក្សាពីចំណុចខាងក្រោម ៖<br>- ស្វែងយល់ពីស្ថានភាពជាក់ស្តែងរបស់សិស្ស និងគ្រួសាររបស់ពួកគេ<br>- ផ្តល់ឧទាហរណ៍ច្បាស់ពីឥរិយាបថមួយចំនួន ដែលមិនអាចទទួលយកបាន<br>- ផ្តល់ឱកាសឱ្យសិស្សជ្រើសរើស និងកែកំហុស<br>- ជួយដោះស្រាយបញ្ហាដោយការគួរសម និងភាពបត់បែន និងពន្យល់ពីឥរិយាបថសមស្រប<br>- ឯកភាពជាមួយសិស្ស និងមាតាបិតា/អាណាព្យាបាលអំពីសារៈសំខាន់នៃការសិក្សា និងឥរិយាបថសមស្រប។ | គ្រូបន្ទុកថ្នាក់ ឬនាយកសាលា គ្រូមុខវិជ្ជា/ មាតាបិតា |

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អន្តរាគមន៍ដែលស្នើឡើង |
|---|---|---|---|
| ៤.១.៥ | សិស្សដែលបែកអារម្មណ៍ក្រៀមក្រំ ឬមិនសូវផ្តោតអារម្មណ៍ក្នុងថ្នាក់<br><br>សិស្សដែលមិនសូវមានមិត្តភក្តិ និងនៅដាច់ឆ្ងាយពីសិស្សផ្សេងទៀត។ | **ការពិគ្រោះយោបល់ និងការដោះស្រាយបញ្ហាសិស្សដែលនៅដាច់ពីគេ** | |
| | | 1. ជួបជាមួយសិស្សដើម្បីស្វែងយល់ថាតើពួកគេមានការលំបាក ឬបញ្ហានៅផ្ទះ ឬសាលា ឬទេ ឬបញ្ជូនពួកគេទៅទីប្រឹក្សាកុមារី ក្រុមប្រឹក្សាកុមារ ឬក្រុមប្រឹក្សាយុវជន។ ព្យាយាមធ្វើឱ្យប្រាកដថាយើងរកឃើញហេតុផលពិត ដោយមិនទទួលចម្លើយដំបូង សូមរកមូលហេតុពិតប្រាកដនិងច្បាស់លាស់បំផុត។ ពេលខ្លះមនុស្សយើងមានការខ្មាស់អៀនក្នុងការបង្ហាញបញ្ហាពិតប្រាកដ។ ពិភាក្សាពីការលំបាករបស់សិស្ស និងឯកភាពលើរបៀបដោះស្រាយបញ្ហានៅផ្ទះ ឬនៅសាលារបស់ពួកគេ។ ប្រសិនបើពួកគេគ្មានមិត្តភក្តិជិតស្និទ្ធ សួរពួកគេពីចំណុចនោះ និងថាតើពួកគេទទួលរងការសម្លុតគំរាមឬទេ។ | គ្រូបន្ទុកថ្នាក់/ ទីប្រឹក្សាកុមារី/ ក្រុមប្រឹក្សាកុមារ |
| | | 2. យកចិត្តទុកដាក់បន្ថែមលើសិស្សនោះនៅក្នុងថ្នាក់ ជាពិសេសកត់សម្គាល់ថាតើពួកគេកែលម្អឥរិយាបថរបស់ខ្លួន ឬទេ។ សួរថាតើពួកគេចង់អង្គុយជិតនរណាម្នាក់ទៀត ឬដាក់ពួកគេឱ្យអង្គុយតុមុខ។ ស្នើឱ្យក្រុមប្រឹក្សាសិស្ស និងប្រធានថ្នាក់ជួយតាមដានសិស្សនោះ ដើម្បីធ្វើយ៉ាងណាកុំឱ្យគាត់ឯកោ ឬទទួលរងការសម្លុតគំរាម។ | គ្រូបន្ទុកថ្នាក់/ គ្រូមុខវិជ្ជា/ ក្រុមប្រឹក្សាកុមារ/ ប្រធានថ្នាក់ |

## ៤.២ អន្តរាគមន៍រយៈពេលវែងផ្សេងទៀតដើម្បីជួយទប់ស្កាត់សិស្សបោះបង់ការសិក្សា

អន្តរាគមន៍ឆ្លើយតបបឋមមានសារៈសំខាន់ព្រោះវាជាជំហានដំបូងដើម្បីទប់ស្កាត់ការបោះបង់ការសិក្សា ប៉ុន្តែចាំបាច់ត្រូវមានផែនការសាលារៀន និងការអនុវត្តអន្តរាគមន៍ចម្រុះសំដៅធ្វើយ៉ាងណាឱ្យសិស្សទទួលបានជំនួយ និងការគាំទ្រចាំបាច់ដើម្បីរួចផុតពីការបោះបង់ការសិក្សា។ អន្តរាគមន៍លើកឡើងមួយចំនួនមានបង្ហាញក្នុងតារាងខាងក្រោម។ គោលការណ៍ណែនាំនេះមិនមែនមានន័យថាជាបញ្ញត្តិបញ្ជានោះទេ ហើយគណៈគ្រប់គ្រងតាមសាលារៀនត្រូវបានលើកទឹកចិត្តធ្វើឱ្យប្រសើរឡើង ឬអនុវត្តន៍គំនិតផ្តួចផ្តើមតាមមូលដ្ឋានដទៃទៀតដែលទាក់ទងនឹងសហគមន៍ និងប្រើប្រាស់បំណិនជីវិតដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រធានបទនានាដែលសំដៅទៅលើតម្រូវការរបស់មូលដ្ឋាន និងភាពលំបាក។ សាលារៀនអាចយោងតាមគោលការណ៍ណែនាំសាលាកុមារមេត្រីស្តីពីអន្តរាគមន៍បន្ថែម និងខ្លឹមសារលម្អិតស្តីពីសកម្មភាពនានា។

<table>
<tr><th>ល.រ</th><th>បញ្ហាដែលកំណត់បាន</th><th>អន្តរាគមន៍ដែលស្នើឡើង</th><th>អ្នកពាក់ព័ន្ធ</th></tr>
<tr><td>៤.២.១</td><td>មាតាបិតាមិនយល់ពីតម្លៃនៃការអប់រំ ឬមិនផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យកូនរៀនសូត្រ។<br><br>សាលាស្ថិតក្នុងតំបន់ដែលសំបូរដោយកុមារធ្វើការ។</td><td>

**ពិធីបុណ្យ បុណ្យជាតិ ការគូសផែនទីសិក្សា និងយុទ្ធនាការប្រមូលសិស្សឱ្យចូលរៀន៖**



ពិធីបុណ្យ បុណ្យជាតិ ការគូសផែនទីសិក្សា និងយុទ្ធនាការប្រមូលសិស្សចូលរៀន ជាឱកាសល្អៗដើម្បីបង្កើនការយល់ដឹងរបស់សហគមន៍ស្តីពីបញ្ហានៃការបោះបង់ការសិក្សា និងអត្ថប្រយោជន៍ និងសិទ្ធិរបស់កុមារក្នុងការបញ្ចប់យ៉ាងហោចណាស់ ការអប់រំមូលដ្ឋាន ដើម្បីឱ្យពួកគេចូលរួមជួយផ្តល់ដំណោះស្រាយ ដែលរក្សាឱ្យកុមារ បន្តការសិក្សា។ គណៈកម្មការ ទប់ស្កាត់ការបោះបង់ការសិក្សា គួររិះរកវិធីផ្តល់ព័ត៌មានជាប្រចាំ ដល់មាតាបិតា សិស្ស គ្រូបង្រៀន និងសហគមន៍អំពី ៖

- ច្បាប់សំខាន់ៗនៅកម្ពុជាដែលធានាសិទ្ធិទទួលបានការអប់រំរបស់កុមារ
- អត្ថប្រយោជន៍នៃការអប់រំ និងសារៈសំខាន់នៃការចុះឈ្មោះកុមារចូលរៀននៅអាយុត្រឹមត្រូវ
- ការចូលរួមចំណែករបស់មាតាបិតាដល់ការបញ្ចប់ការសិក្សារបស់កូន។

សាលាគួរផ្សព្វផ្សាយទូលំទូលាយដល់សិស្ស មាតាបិតា និងសហគមន៍ពីសេវាគាំទ្រដែលមានក្នុងសាលាដើម្បីធ្វើយ៉ាងណាឱ្យកុមារអាចបញ្ចប់ការសិក្សា និងអាចស្វែងរកជំនួយដោយងាយស្រួល។ ផ្តល់ព័ត៌មានដល់មាតាបិតា និងសហគមន៍ឱ្យបានដឹងពីសកម្មភាពទាំងនេះ និងមូលនិធិចាំបាច់ដើម្បីផ្តល់ធនធានដល់សកម្មភាពទាំងនោះ។ សូមមើលផ្នែក ២.៦ ស្តីពីខ្លឹមសារលម្អិតនៃព័ត៌មានសំខាន់មួយចំនួនដែលត្រូវផ្សព្វផ្សាយ។ សាលាគួរខិតខំប្រើប្រាស់មធ្យោបាយល្អៗដើម្បីផ្សព្វផ្សាយព័ត៌មាន ដែលរួមបញ្ចូល ប៉ុន្តែមិនកម្រិតត្រឹម ៖ ការបង្កើតបដា និងពាក្យស្លោកក្នុងយុទ្ធនាការ ការរៀបចំការប្រឡងសិល្បៈ កំណាព្យ ឬសំណេររឿង ការសម្តែងតួ ការនិទានរឿង និងការបណ្តុះបណ្តាល

</td><td>- គណៈគ្រប់គ្រងសាលា<br>- មន្ត្រីទទួលបន្ទុកការងារ<br>- ក្រុមប្រឹក្សាកុមារ/យុវជន<br>- ព្រះសង្ឃ<br>- គណៈកម្មការអាចារ្យវត្ត<br>- មាតាបិតាអាណាព្យាបាល និងសិស្ស</td></tr>
</table>

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| | | មាតាបិតា និងសហគមន៍ក្នុងកិច្ចប្រជុំ។ ករណីសិក្សានៅក្នុង ឧបសម្ព័ន្ធ ៥.៨ អាចសមស្របសម្រាប់ប្រើជាមួយក្រុមប្រឹក្សាកុមារ និងសហគមន៍ ហើយអាចប្តូរទៅជាការសម្តែងតួ ដើម្បីសម្តែងនៅក្នុងពិធីទិវាជាតិ។ | |
| ៤.២.២ | កង្វះសម្ភារសិក្សា ឬ មធ្យោបាយធ្វើដំណើរទៅសាលារៀន | <br><br>កម្មវិធីអាហារូបករណ៍<br><br>សិស្សក្រីក្រមិនសូវមានលទ្ធភាពទិញសូម្បីតែសម្ភារសិក្សាចាំបាច់ដូចជា សៀវភៅលំហាត់ ប៊ិក សម្ភារសិក្សាគណិតវិទ្យា ឬឯកសណ្ឋាន។ សាលាអាចប្រើប្រាស់មូលនិធិអាហារូបករណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា និងមូលនិធិរបស់ម្ចាស់ជំនួយ ឬសហគមន៍ដើម្បីទិញសម្ភារសិក្សាសំខាន់ៗដល់ពួកគេ និងគួរជួយទិញកង់ ប្រសិនបើសិស្សទាំងនោះរស់នៅឆ្ងាយពីសាលា និងមិនអាចធ្វើដំណើរជាមួយសិស្សផ្សេងទៀតបាន។ ដើម្បីជួយកៀរគរមូលនិធិបន្ថែមសម្រាប់ទិញសម្ភារសិក្សាឱ្យសិស្សក្រីក្រ។ សាលាអាចរៀបចំកម្មវិធីផ្សេងៗ ដូចជា ៖<br><br>- ក្រុមប្រឹក្សាកុមារអាចបង្កើតប្រអប់បរិច្ចាគ ដើម្បីប្រមូលវិភាគទានតិចតួចពីសិស្សដែលមានលុយទិញនំចំណី ២ទៅ៣ថ្ងៃនៅដងទង់ជាតិ( តាមលទ្ធភាព )។ ក្រុមប្រឹក្សាកុមារគួរចូលរួមកត់ត្រាចំនួនប្រាក់ប្រមូលបាន និងសម្រេចចិត្តលើការចាយវាយ។<br>- សាលា និងសហគមន៍អាចបង្កើតប្រអប់មូលនិធិនៅវត្តអារាម ឬទីគោរពបូជាផ្សេងទៀត ឬក្នុងមជ្ឈមណ្ឌលសហគមន៍។<br>- ការរៃអង្គាសអាចធ្វើឡើងនៅតាមព្រឹត្តិការណ៍ពិសេសៗ ដូចជា បុណ្យជាតិ បុណ្យផ្កា ឬការលក់សំបុត្រចាប់ឆ្នោត ឬព្រឹត្តិការណ៍រៃអង្គាសផ្សេងទៀត។ | គណៈកម្មការគ្រប់គ្រងតាមសាលារៀន<br><br>គណៈកម្មការទ្រទ្រង់សាលា<br><br>គ្រូបង្រៀន<br>មាតាបិតា<br>ក្រុមប្រឹក្សាកុមារ |

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| ៤.២.៣ | លទ្ធផលសិក្សាទាប ៖ មុខវិជ្ជាណាមួយជាពិសេស ភាសាខ្មែរ និង គណិតវិទ្យា | លទ្ធផលសិក្សាទាបអាចបង្កជាបញ្ហា និងធ្វើឱ្យសិស្សបោះបង់ការសិក្សា។ សិស្សដែលរៀនយឺតមុខវិជ្ជាភាសាខ្មែរងាយនឹងបោះបង់ការសិក្សា ព្រោះមុខវិជ្ជាផ្សេងទៀតទាមទារនូវជំនាញអំណាន និងសំណេរល្អប្រសើរ ដើម្បីឱ្យសិស្សឡើងថ្នាក់បាន។ គណិតវិទ្យាក៏ជាមុខវិជ្ជាមួយដែលសាលាគួរយកចិត្តទុកដាក់ជាពិសេសដើម្បីធានាថា សិស្សទាំងអស់អាចរៀនទាន់។ ដូច្នេះ ត្រូវផ្តល់ជំនួយពិសេសដល់សិស្ស នៅពេលកំណត់បានសិស្សដែលរៀនយឺតភាសាខ្មែរ និងគណិតវិទ្យា រួចទើបផ្តោតលើមុខវិជ្ជាផ្សេងទៀត។ ក្នុងការផ្តល់ជំនួយ សាលាមានវិធីជាច្រើន ដូចជា ៖<br><br>- **ការដាក់ឱ្យសិស្សរៀនយឺតអង្គុយជាមួយសិស្សពូកែ** ដើម្បីឱ្យសិស្សពូកែជួយសិស្សរៀនយឺត ប៉ុន្តែប្រហែលជាត្រូវមានការណែនាំពីគ្រូ ដូចជា ស្នើសុំឱ្យសិស្សពូកែបញ្ចប់កិច្ចការរួច ទើបជួយឱ្យសិស្សរៀនយឺតបញ្ចប់កិច្ចការតាមក្រោយ។ <br><br>- **មិត្តជួយមិត្ត ៖** ជាជំនួយរបស់សិស្សពូកែដល់សិស្សរៀនយឺតដែលអវត្តមាន ដើម្បីឱ្យរៀនទាន់គេ និង/ឬសម្ភារស្វ័យសិក្សាសម្រាប់សិស្សដែលអវត្តមានយូរ ដូចជា ដោយសារតែជំងឺ ឬគ្រោះថ្នាក់។<br><br>- **សិស្សច្បងជួយដល់សិស្សប្អូន ៖** ឧ.សិស្សថ្នាក់ទី៥និងទី៦ អាចស្ម័គ្រចិត្តជួយដល់សិស្សថ្នាក់ទី១-៣ ក្នុងការអនុវត្តការសរសេរតួអក្សរ អានពាក្យធម្មតា និងលេងល្បែងពាក្យ និងល្បែងគណិតវិទ្យាធម្មតាជាមួយសិស្សប្អូនក្នុងម៉ោងសម្រាកនៅតាមកន្លែងដែលអាចជួបជុំគ្នាបាន ឬពេលចូលបណ្ណាល័យ។<br><br>- **ការផ្តល់ការគាំទ្រផ្នែកភាសាដល់សិស្សដែលមិននិយាយភាសាខ្មែរជាភាសាកំណើត** ជាពិសេសសិស្សរស់នៅក្នុងតំបន់ដែលមានកុមារជនជាតិដើមភាគតិចច្រើន តាមរយៈការជ្រើសរើសគ្រូដែលនិយាយទាំងភាសាជនជាតិភាគតិច និងភាសាខ្មែរ ឬសុំឱ្យសមាជិកសហគមន៍ដែលចេះនិយាយទាំងពីរភាសាផ្តល់ជំនួយភាសាក្នុងថ្នាក់។ | គ្រូបន្ទុកថ្នាក់<br>គ្រូមុខវិជ្ជា<br>ក្រុមប្រឹក្សាកុមារ<br>ប្រធានថ្នាក់<br>សិស្សរៀនលឿន<br>សមាជិកសហគមន៍ |

| លរ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| | | <br>- **ក្លឹបសិក្សា** អាចរៀបចំឡើងទៅតាមមុខវិជ្ជាដោយសិស្សផ្ទាល់( សិស្សធំ ) ដោយមានសិស្សពូកែដឹកនាំក្លឹប និងស្នើសុំជំនួយខ្លះៗពីគ្រូនៅពេលចាំបាច់ ឬដោយមានជំនួយពីសិស្សច្បង សមាជិកសហគមន៍ ឬគ្រូក្រៅម៉ោងសិក្សា( សិស្សតូច )។ ក្លឹបនេះអាចរៀបចំឡើងក្នុងសាលា ឬសហគមន៍។ ប្រធានក្លឹប អាចជួយពន្យល់ពីចំណុចលំបាកនានាក្នុងមេរៀន ហើយសមាជិកក្លឹបអាចសួរសំណួរ ឬអនុវត្តសកម្មភាពលំបាកៗ។ គុណសម្បត្តិនៃការមានសិស្សគ្រប់គ្រងក្លឹបនេះគឺពេលខ្លះពួកគេមានភាពងាយស្រួលក្នុងការស្នើសុំជំនួយពីមិត្តភក្តិជាងពីគ្រូ។ នាយកសាលាត្រូវចែកកាលវិភាគសិក្សាដល់សិស្សដើម្បីសិក្សាក្នុងក្លឹបសិក្សា ហើយគ្រូបន្ទុកថ្នាក់ត្រូវសហការជាមួយគ្រូមុខវិជ្ជាដើម្បីរៀបចំដាក់សិស្សពូកែជាមួយសិស្សរៀនយឺត។ គ្រូមុខវិជ្ជាគឺជាទីប្រឹក្សាក្លឹប ( ផ្តល់យោបល់ ) ចំណែកអាណាព្យាបាលគួរផ្តល់ឱកាសឱ្យសិស្សមានពេលវេលាបន្ថែមក្រៅម៉ោងសិក្សាសាលារដ្ឋ។ | |
| | | - **ការយកចិត្តទុកដាក់បន្ថែមពីគ្រូបង្រៀនក្នុងថ្នាក់ ៖** គ្រូគួរយកចិត្តទុកដាក់ជាពិសេសលើសិស្សរៀនយឺតនៅពេលត្រួតពិនិត្យថ្នាក់ និងផ្តល់ជំនួយផ្ទាល់ខ្លួនដល់ពួកគេ។ គ្រូអាចហៅឱ្យសិស្សរៀនយឺតឆ្លើយសំណួរដែលពួកគេចេះដើម្បីបង្កើនទំនុកចិត្ត និងទុកសំណួរពិបាកឱ្យសិស្សពូកែឆ្លើយ។នាយកត្រូវដឹកនាំត្រូវធ្វើតេស្តស្តង់ដានៅដើមឆ្នាំសិក្សាលើសិស្សថ្នាក់ទី៧ដែលទើបឡើងពីថ្នាក់ទី៦ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ហើយលទ្ធផលតេស្តដើម្បីជួយសិស្សរៀនយឺត។ | |
| | | - **មេរៀនបន្ថែម ៖** សម្រាប់សិស្សដែលរៀនមិនទាន់គេ។ នេះជាការសំខាន់បំផុតសម្រាប់សិស្សដែលខ្សោយអំណាន និងសំណេរភាសាខ្មែរ។ ចំណុចនេះជួយបានច្រើន ប្រសិនបើត្រូវមានជំនួយបន្ថែមសម្រាប់សិស្សមួយក្រុមតូច ឬសិស្សម្នាក់ៗ។ ទោះបីជាថ្នាក់ប្រភេទនេះត្រូវបានចាត់ទុកជា “ការរៀនបន្ថែម” វាជារឿងសំខាន់ចំពោះសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សាមិនត្រូវបានផាត់ចេញពីថ្នាក់រៀនបន្ថែម ប្រសិនបើពួកគេមិនមានលទ្ធភាពគ្រប់គ្រាន់សម្រាប់បង់ថ្លៃសិក្សា។ | |

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អ្នកពាក់ព័ន្ធ |
| --- | --- | --- | --- |
| | | - **ការប្រើប្រាស់កម្មវិធីស្មាតហ្វូន និងកុំព្យូទ័របន្ទះ** ដើម្បីជួយបង្កើនសមត្ថភាព និងការធ្វើតេស្តអំណាន គណិតវិទ្យា និងផ្តល់ចំណេះដឹងពីមុខវិជ្ជាផ្សេងទៀត។ មានអង្គការជាច្រើនសហការជាមួយក្រសួង អប់រំ យុវជន និងកីឡា ដើម្បីផលិតឯកសារគាំទ្រ ដែលមានក្នុងកុំព្យូទ័របន្ទះតាមបណ្ណាល័យក្នុងសាលា ឬស្មាតហ្វូនតាមគ្រួសារ។ ទំព័រហ្វេសប៊ុក All Children Reading-Cambodia ជាប្រភពដ៏ល្អដែលផ្តល់ឯកសារអំណានបន្ថែមដោយមិនគិតថ្លៃ និងអាចទាញយក(Download)បាន។ តំណភ្ជាប់ ៖ www.facebook.com/allchildrenreadingcambodia)។ | |
| | | - **កម្រិតអំណាន** សាលាគួរយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពអំណានសិស្សថ្នាក់ដំបូងតាមរយៈការធ្វើតេស្តតាមដំណាក់កាលនៃមេរៀន ដើម្បីវាស់ស្ទង់កម្រិតអំណាន និងផ្តល់ការអន្តរាគមន៍ទាន់ពេលតាមរយៈការប្រើប្រាស់កម្មវិធីតេស្តដំណាក់កាលអំណាន ដែលមាននៅក្រសួងអប់រំ យុវជន និងកីឡា(តាមថេប្លេត ស្មាតហ្វូន ឬតាមសន្លឹកតេស្ត)។ មានកម្មវិធីមួយសម្រាប់សិស្ស (តេស្តអំណានសម្រាប់សិស្ស) ៖ https://play.google.com/store/apps/details?id=com.cammob.test_app.student និងកម្មវិធីមួយសម្រាប់គ្រូ (តេស្តអំណានសម្រាប់គ្រូ) ៖ https://play.google.com/store/apps/details?id=com.cammob.test_app.teacher | |
| | | - **ធនធានបន្ថែមតាមបណ្តាញអ៊ីនធឺណិត** មានក្នុង ឧបសម្ព័ន្ធ ៥.៧ ៖ ធនធានបន្ថែមសម្រាប់ជួយដល់ស្វ័យសិក្សា។ សាលារៀនអាចណែនាំមាតាបិតា ឬអាណាព្យាបាលសិស្សដែលប្រើប្រាស់ ស្មាតហ្វូន ឱ្យទាញយកកម្មវិធីពង្រឹងអំណាន និងគណិតវិទ្យា ថ្នាក់បឋមសិក្សា ដើម្បីជួយកូនក្នុងការរៀនសូត្រនៅផ្ទះ។ | |

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| ៤.២.៤ | សិស្សជាច្រើនមានអាយុច្រើនធៀបនឹងកម្រិតថ្នាក់។ | **ថ្នាក់ពន្លឿន** ៖ សាលារៀបចំថ្នាក់ពន្លឿនក្នុងសាលាសម្រាប់សិស្សដែលមានអាយុច្រើនធៀបនឹងកម្រិតថ្នាក់របស់ខ្លួន ដើម្បីឱ្យពួកគេអាចពន្លឿនការសិក្សារបស់ខ្លួន និងអាចចូលរៀនថ្នាក់សមស្របតាមអាយុជាមួយសិស្សស្រករគ្នា។ សកម្មភាពទាំងនេះអាចរៀបចំឡើងដូចខាងក្រោម ៖<br><br><br>- បង្កើតកម្មវិធីសិក្សាពន្លឿន ដើម្បីឱ្យសិស្សមានអាយុច្រើនធៀបនឹងកម្រិតថ្នាក់ អាចរៀនពីរថ្នាក់ក្នុងមួយឆ្នាំសិក្សា។ មានន័យថា ពួកគេអាចបញ្ចប់ថ្នាក់បឋមសិក្សាក្នុងរយៈពេលតែ ៣ ឆ្នាំ (ថ្នាក់ទី១ = ថ្នាក់ទី១ + ថ្នាក់ទី២, ថ្នាក់ទី២ = ថ្នាក់ទី៣+ ថ្នាក់ទី៤, ថ្នាក់ទី៣ = ថ្នាក់ទី៥ + ថ្នាក់ទី៦)។<br>- សិស្សមានអាយុច្រើនអាចចុះឈ្មោះចូលរៀនថ្នាក់ណាមួយ ទៅតាមភាពសមស្រប និងអាចដាក់បញ្ចូលក្នុងថ្នាក់ធម្មតាណាមួយទៅតាមវ័យ និងសមត្ថភាពរបស់ពួកគេ។ | គ្រូថ្នាក់ពន្លឿន |
| | | **ថ្នាក់សមាហរណកម្ម** ៖ អាជ្ញាធរមូលដ្ឋានសហការជាមួយសាលារៀនដើម្បីរៀបចំប្រព័ន្ធអប់រំក្រៅផ្លូវការ សម្រាប់សិស្សបោះបង់ការសិក្សា ដើម្បីឱ្យពួកគេអាចបន្តការសិក្សាឡើងវិញបាន។ ថ្នាក់នេះស្រដៀងគ្នានឹងថ្នាក់ពន្លឿន ប៉ុន្តែវាជាប្រព័ន្ធអប់រំក្រៅផ្លូវការ។ | គ្រូដែលចាត់តាំង |

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| ៤.២.៥ | សិស្សដែលឃ្លានក្នុងម៉ោងសិក្សា។ | **កម្មវិធីអាហារូបត្ថម្ភនិងកម្មវិធីផ្តល់អាហារនៅសាលា៖**ក្នុងតំបន់មួយចំនួនមាតាបិតាមានការលំបាកក្នុងការផ្តល់អាហារពេលព្រឹកដល់កុមារ មុនពេលទៅរៀន ព្រោះពួកគាត់ត្រូវចេញទៅធ្វើការតាំងពីព្រឹក។ កុមារក្រីក្រមានការលំបាកក្នុងការទិញអាហារនៅជិតសាលា ហើយពួកគេអាចឃ្លានក្នុងម៉ោងសិក្សា។ ក្នុងតំបន់ខ្លះអាចមានម្ចាស់ជំនួយផ្តល់វិភាគទានអាហារ ប៉ុន្តែនៅតំបន់ដែលគ្មានម្ចាស់ជំនួយ សហគមន៍ និងមាតាបិតាអាចបរិច្ចាគប្រាក់តិចតួចរាល់ថ្ងៃ ដើម្បីរៀបចំកម្មវិធីផ្តល់អាហារពេលព្រឹក ឬថ្ងៃត្រង់។ សិស្សដែលមិនអាចបរិច្ចាគបាន អាចញ៉ាំដោយមិនគិតថ្លៃ និងជួយរៀបចំកម្មវិធីនេះ។ សហគមន៍ និងសិស្សគួររៀបចំកម្មវិធីនេះនៅសាលា និងជួយចម្អិន និងលាងសម្អាតចាន។ សំខាន់បំផុត សិស្សត្រូវតែបានញ៉ាំអាហារពេលព្រឹកដើម្បីឱ្យពួកគេអាចផ្តោតអារម្មណ៍លើការសិក្សាបាន។ | មាតាបិតា<br>សហគមន៍<br>ក្រុមប្រឹក្សាកុមារ<br>និងសិស្ស<br>ផ្សេងទៀត |
| ៤.២.៦ | សិស្សមានបញ្ហាសុខភាព<br><br>សិស្សមិនអាចមករៀនដោយសារពិការភាព។<br><br>ក្មេងស្រីមិនចូលរួមដោយសារតែគ្មានបង្គន់អនាម័យគ្រប់គ្រាន់ | **ការពិនិត្យសុខភាព ៖** សាលាត្រូវពិនិត្យសុខភាព និងផ្តល់សេវាសុខភាពដល់សិស្សជាប្រចាំដើម្បីអាចឱ្យពួកគេអភិវឌ្ឍរាងកាយ ស្មារតី សតិបញ្ញា និងចំណាប់អារម្មណ៍ដើម្បីរៀនសូត្រដោយប្រសិទ្ធភាព។ ដូច្នេះសាលាត្រូវរៀបចំផែនការដោយសហការ <br>ជាមួយគណៈកម្មការទទួលខុសត្រូវសាលារៀននិងមណ្ឌលសុខភាពដើម្បីរៀបចំ៖<br>- តារាងវាស់កម្ពស់ និងទម្ងន់សិស្សប្រចាំខែ<br>- សៀវភៅកត់ត្រាសុខភាពសម្រាប់សិស្សម្នាក់ៗ ដែលសម្រួលដល់ការពិនិត្យសុខភាពជាប្រចាំ<br>- ការចាក់ថ្នាំបង្ការ ( ទម្លាក់ព្រូន...)<br>- កម្មវិធីពិនិត្យសុខភាពមាត់ ធ្មេញ ភ្នែក ត្រចៀក និងការលាងសម្អាតដៃ<br>- កៀរគរថវិកាទិញសម្ភារបរិក្ខារសម្រាប់សិស្សពិការ។ | គ្រូបន្ទុកថ្នាក់<br>មណ្ឌល<br>សុខភាព |

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អ្នកពាក់ព័ន្ធ |
| --- | --- | --- | --- |
| | | **តម្រូវការពិសេស ៖** កុមារទាំងអស់សុទ្ធតែមានសិទ្ធិចូលរៀន និងសិក្សាដោយគ្មានការរើសអើង។ ដើម្បីធានាថា កុមារគ្រប់រូបអាចសិក្សាបាន សាលាគួរកំណត់អត្តសញ្ញាណសិស្សពិការ ឬមានតម្រូវការរៀនសូត្របន្ថែម និងធ្វើការកែសម្រួលសមស្របដើម្បីឱ្យពួកគេអាចសិក្សាបាន។ យកល្អគួរបង្កើតកំណត់ត្រាករណី ឬផែនការសិក្សាផ្ទាល់ខ្លួនសម្រាប់សិស្សពិការ ឬមានតម្រូវការពិសេស និងគ្រោងផ្តល់ជំនួយបន្ថែមចាំបាច់។ ការកែសម្រួលរួមមាន ៖ កៅអីដោយឡែកមួយ ការអង្គុយនៅជិតក្តារខៀន ឬគ្រូ ប្រសិនបើពួកគេមានបញ្ហាគំហើញ ឬការស្តាប់ ការរៀបចំថ្នាក់ឡើងវិញដើម្បីសម្រួលដល់រទេះរុញ ការសរសេរអក្សរធំៗ ឯកសារបង្រៀនពិសេស ការដាក់សំណួរ និងកិច្ចការទៅតាមសមត្ថភាពរបស់សិស្ស ការគាំទ្រផ្នែកភាសា។<br><br>សាលាក៏គួរតែរៀបចំផ្លូវជម្រាលតាមមុំតូចសមរម្យសម្រាប់អគារសិក្សា បង្គន់និងកន្លែងផ្សេងៗទៀត ដើម្បីឱ្យសិស្សជិះរទេះរុញអាចធ្វើចលនាបានដោយមិនត្រូវការជំនួយ និងអាចចូលរួមគ្រប់សកម្មភាពទាំងអស់បាន។ សាលាគួរធានាថាច្រករបៀង និងផ្លូវត្រូវបានរក្សាឱ្យច្បាស់ពីឧបសគ្គដែលអាចពិបាកសម្រាប់អ្នកជិះរទេះរុញ ឬអ្នកដែលមានបញ្ហាចរាចរណ៍ផ្សេងទៀតនិងអ្នកដើរដោយប្រើឈើច្រត់។ នេះរួមបញ្ចូលទាំងការធានាថាស្បែកជើងត្រូវបានរក្សាទុកយ៉ាងរៀបរយនៅខាងក្រៅបន្ទប់រៀន ដូច្នេះទើបមិនរំខានដល់ផ្លូវចូល។ | គ្រូបន្ទុកថ្នាក់ នាយកសាលា កុមារដែលមានតម្រូវការពិសេស និងអ្នកអាណាព្យាបាល |
| | | **WASH ( ទឹកស្អាត, អនាម័យ និងគ្រឿងបរិក្ខារអនាម័យ )** អវត្តមាននៃ WASHគឺជាបញ្ហាប្រឈមពិសេសមួយសម្រាប់ក្មេងស្រីជំទង់ទាំងនៅក្នុងសាលាបឋមសិក្សា និងអនុវិទ្យាល័យ និងសាលារៀន។ កង្វះអនាម័យក៏អាចបណ្តាលឱ្យមានជំងឺរាគ និងការឆ្លងតាមផ្លូវដង្ហើមបណ្តាលឱ្យមានបញ្ហាអវត្តមាន និងធ្វើឱ្យការសិក្សានៅមានកម្រិតទាប។<br><br>សាលារៀនទាំងអស់ត្រូវធានាថាមានបង្គន់គ្រប់គ្រាន់សំរាប់សិស្សទាំងអស់ប្រើរួមទាំងសិស្សស្រីនិងសិស្សពិការ។ បទដ្ឋានជាតិនេះរំពឹងថាសាលារៀនមានបង្គន់យ៉ាងហោចណាស់ ២ និងបង្គន់នោម ៣ សម្រាប់ក្មេងប្រុស ១០០នាក់ និងបង្គន់អនាម័យ ៣ សម្រាប់ក្មេងប្រុស ១០០នាក់។ ក្នុងករណីដែលសាលាគ្មានបង្គន់អនាម័យ ឬបង្គន់អនាម័យដែលហួសពីការជួសជុលនោះសាលាគួរតែបញ្ជូនសំណើទៅការិយាល័យអប់រំស្រុកហើយធានាថា:<br><br>- បង្គន់ត្រូវអាចបើកសោរពីខាងក្រៅក្នុងម៉ោងសិក្សា និងអាចប្រើប្រាស់បានគ្រប់ពេល<br><br>- មានបង្គន់ដោយឡែកសម្រាប់សិស្សប្រុស និងសិស្សស្រី | នាយកសាលា គណៈកម្មការគ្រប់គ្រងតាមសាលារៀន សហគមន៍ និងការិយាល័យអយកស្រុក |

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| | | - សញ្ញាសម្រាប់សិស្សប្រុស សិស្សស្រី និងសិស្សពិការ<br>- យ៉ាងហោចណាស់បង្គន់មួយត្រូវមានជម្រាលសមស្រប សម្រាប់សិស្សពិការ និងបង្កាន់ដៃប្រសិនបើចាំបាច់។<br>- ទ្វារគួរមានការថែទាំបានល្អ និងគួរមានរនុកទ្វារដំណើរការល្អ ដើម្បីអាចចាក់សោរពីខាងក្នុងដើម្បីរក្សាភាពឯកជន។<br><br>- គួរផ្តល់ការណែនាំពីរបៀបប្រើប្រាស់បង្គន់ និងគួរពង្រឹង ការណែនាំជាប្រចាំ ជាពិសេសសម្រាប់សិស្សថ្នាក់ទាប<br>- គួររក្សាឱ្យបង្គន់ស្អាត និងមានអនាម័យ ហើយគួរបង្កើតប្រព័ន្ធមួយដើម្បីធានាថា បង្គន់ស្អាតរាល់ថ្ងៃ និងត្រូវបានត្រួតពិនិត្យនៅម៉ោងចេញលេង។ ក្រុមប្រឹក្សាកុមារអាចពិនិត្យប្រព័ន្ធនេះដោយសហការជាមួយសាលារៀន។<br>- គួរមានសម្ភារសម្អាតបន្ទប់ទឹក ( ទឹក ច្រាស និងសាប៊ូម្សៅ... )<br>- គួរមានធុងសំរាមអនាម័យក្នុងបង្គន់ ជាពិសេសក្នុងបង្គន់ស្ត្រី និងគួរមានផ្តល់សំឡីអនាម័យដល់ក្មេងស្រីសម្រាប់ករណីបន្ទាន់។ | |
| ៤.២.៧ | មានក្តីកង្វល់ពីសុវត្ថិភាព/សន្តិសុខក្នុងតំបន់ | **ការធ្វើដំណើរជាក្រុម និងទាក់ទងទៅអាជ្ញាធរមូលដ្ឋានដើម្បីបង្កើនសន្តិសុខ ៖** ជួយផ្តល់សន្តិសុខដល់កុមារ ពិសេសកុមារី ដែលអាចមានការលំបាកក្នុងការធ្វើដំណើរទៅមកសាលា តាមរយៈការរៀបចំសិស្សជាក្រុម ឬធ្វើដំណើរជាមួយពួកគេឆ្លងកាត់តំបន់គ្រោះថ្នាក់ ឬតំបន់ដែលមានហានិភ័យសន្តិសុខ។ ប្រសិនបើចាំបាច់ គួរទាក់ទងទៅអាជ្ញាធរមូលដ្ឋានដើម្បីធានាសុវត្ថិភាពផ្លូវ និងស្នើឱ្យអ្នកដឹកនាំសហគមន៍ជួយតាមដានសិស្សតាមផ្លូវទៅសាលា។ | គ្រូបន្ទុកថ្នាក់<br>នាយកសាលា<br>អាជ្ញាធរមូលដ្ឋាន<br>មន្ត្រីមានសមត្ថកិច្ច |

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| ៤.២.៧ | សិស្សបោះបង់ការសិក្សានៅចន្លោះថ្នាក់ទី ៦ និងទី ៧ | **ការតម្រង់ទិសសម្រាប់សិស្សដែលត្រូវឆ្លងភូមិសិក្សាទៅកម្រិតអប់រំបន្ទាប់ ៖** <br>- រៀបចំតម្រង់ទិស នៅពាក់កណ្ដាលឆ្នាំសិក្សាដល់សិស្សថ្នាក់ទី៦ ដោយសហការជាមួយតំណាងរបស់សាលាមធ្យមសិក្សា ក្នុងមូលដ្ឋានស្ដីពីការសិក្សា នៅអនុវិទ្យាល័យឈ្មោះសាលា ដែលពួកគេត្រូវបន្តការសិក្សាមុខវិជ្ជា របៀបប្រើប្រាស់កាលវិភាគសាលា (ឧ. មានគ្រូបង្រៀនផ្សេងគ្នាសម្រាប់មុខវិជ្ជានីមួយៗតាមឯកទេស) ប្រតិទិនសាលា ចម្ងាយផ្លូវ និងមធ្យោបាយធ្វើដំណើរទៅសាលា ការគាំទ្រ និងសកម្មភាពដែលមាននៅសាលាថ្មី។<br>- ឱ្យសិស្សពិភាក្សាក្នុងក្រុមពីរបៀបទៅដល់សាលានៅថ្ងៃទីមួយ និងអ្នកដែលត្រូវទៅជាមួយ (បងប្អូនបង្កើត មិត្តភក្តិ មាតាបិតា/អាណាព្យាបាល) និងការគិតរបស់ពួកគេអំពីសាលាថ្មី និងគុណសម្បត្តិ និងក្ដីកង្វល់របស់ពួកគេ។ គ្រូត្រូវកត់ត្រារាល់ក្ដីកង្វល់ដែលលេចឡើង ជាពិសេសសិស្សដែលងាយបោះបង់ការសិក្សា។ កំណត់ត្រានោះគួរត្រូវបានចែករំលែកដោយសាលាបឋមសិក្សា និងសាលាដែលសិស្សត្រូវទៅរៀនបន្ត។<br>- អញ្ជើញឱ្យមាតាបិតាមកកាន់សាលា ដើម្បីឱ្យពួកគាត់គិតពីបញ្ហាប្រឈមរបស់កូនក្នុងការឆ្លងភូមិសិក្សាទៅសាលាមធ្យមសិក្សា និងស្ដាប់យោបល់របស់សិស្ស និងគ្រូមធ្យមសិក្សាបឋមភូមិពីរបៀបដោះស្រាយ។ ប្រាប់មាតាបិតាពីកម្មវិធីអាហារូបករណ៍ និងកម្មវិធីគាំទ្រផ្សេងទៀត ហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពដែលមាននៅអនុវិទ្យាល័យ។ ជំរុញឱ្យមាតាបិតា អាណាព្យាបាលគិតពីសារៈសំខាន់នៃការជំរុញឱ្យកូនបន្តការសិក្សា។ ប្រសិនបើអាច អញ្ជើញឱ្យមាតាបិតាដែលខិតខំឱ្យកូនបន្តការសិក្សា ឡើងនិយាយពីរបៀបជម្នះឧបសគ្គ និងគុណសម្បត្តិនៃការឱ្យកូនបន្តការសិក្សា។ គ្រូគួរកត់ត្រាពីក្ដីកង្វល់ដែលលើកឡើងដោយមាតាបិតាឬអ្នកអាណាព្យាបាល និងសិស្សដែលពួកគេយល់ថាអាចនឹងមិនទៅចុះឈ្មោះចូលរៀននៅកម្រិតបន្ទាប់ និងបញ្ហាប្រឈមធំៗ។ ច្បាប់ចម្លងបញ្ជីនេះគួររក្សាទុកដោយសាលាបឋមសិក្សា និងសាលាដែលសិស្សត្រូវឆ្លងទៅរៀនបន្ត។ | - នាយកសាលាមធ្យម<br>- នាយកសាលាបឋម<br>- គ្រូថ្នាក់ថ្នាក់ទី៦, ទី៧<br>- សិស្សគំរូថ្នាក់ទី៧ និងអ្នកពាក់ព័ន្ធ |

| ល.រ | បញ្ហាដែលកំណត់បាន | អន្តរាគមន៍ដែលស្នើឡើង | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| | | - ប្រសិនបើអាច រៀបចំទស្សនកិច្ចសិក្សាដល់សិស្សថ្នាក់ទី ៦ ទៅអនុវិទ្យាល័យដែលពួកគេនឹងត្រូវបន្តការសិក្សានៅឆ្នាំបន្ទាប់ និងត្រៀមផែនការជាស្រេច ឬប្រសិនបើមិនអាច អញ្ជើញសិស្សមួយក្រុមតូចមកពីអនុវិទ្យាល័យទៅកាន់សាលាបឋមសិក្សា ឬបង្ហាញវីដេអូស្ដីពីសាលាថ្មី។<br>- បង្កើតឱ្យមានកម្មវិធីមិត្តជួយមិត្តរវាងសិស្សថ្នាក់ទី៦ និងរៀមច្បងនៅអនុវិទ្យាល័យ ដើម្បីពន្យល់ពីការធ្វើដំណើរទៅមក និងរបៀបដែលពួកគេជម្នះការលំបាកក្នុងការសិក្សា និងរក្សាតុល្យភាពការងារនៅផ្ទះ។ លើកទឹកចិត្តឱ្យរៀមច្បងធ្វើជាអ្នកណែនាំដល់សិស្សប្អូន នៅពេលទៅរៀនថ្នាក់ទី៧ ដើម្បីឱ្យពួកគេមានអ្នកពិភាក្សាពីបញ្ហា និងដំណោះស្រាយ។<br>- ក្នុងករណីដែលអាចសាលាគួរបង្កើតឱ្យមានសេវាប្រឹក្សាអាជីព ដើម្បីតម្រង់ទិសសិស្សក្នុងការសម្រេចចិត្តសិក្សាទៅថ្ងៃអនាគត និងឱកាសការងារ។ | |
| ៤.២.៩ | សាលារៀនជាញឹកញាប់ត្រូវបានជន់លិចនៅដើមឆ្នាំសិក្សា<br><br>សិស្សអវត្តមានជាញឹកញាប់ក្នុងរដូវប្រមូលផល ឬដោយសារការធ្វើចំណាកស្រុកតាមរដូវ | **វិមជ្ឈការកាលវិភាគ**<br>ក្រសួងអប់រំ យុវជន និងកីឡាបានអនុញ្ញាតឱ្យសាលារៀនសម្របខ្លួនតាមប្រតិទិនសាលារៀននៅតាមតំបន់របស់ពួកគេដើម្បីរៀបចំបទប្បញ្ញត្តិពិសេសសម្រាប់ការសិក្សានៅតាមតំបន់ដែលសិស្សជាច្រើននឹងត្រូវអវត្តមានសម្រាប់ឆ្នាំសិក្សាមួយ។<br><br>កាលវិភាគតាមបែបវិមជ្ឈការអនុញ្ញាតឱ្យសាលារៀនចាប់ផ្ដើម និងបញ្ចប់ឆ្នាំសិក្សាមុន ឬក្រោយ ដោយអាស្រ័យទៅតាមតម្រូវការក្នុងតំបន់។ វាក៏អនុញ្ញាតឱ្យសាលារៀនចាប់ផ្ដើម និងបញ្ចប់កាលវិភាគប្រចាំថ្ងៃមុនពេលដើម្បីធានាថាសិស្សអាចចូលរួមបាន។ | នាយកសាលា<br>សហគមន៍<br>ការិយាល័យស្រុក |

# ៥. ឧបសម្ព័ន្ធ

## ៥.១ ទម្រង់របាយការណ៍ចុះតាមផ្ទះ ( គំរូ )

កាលបរិច្ឆេទចុះទៅដល់ផ្ទះ៖.....................................ឈ្មោះអ្នកចុះតាមផ្ទះ៖............................

តួនាទី៖.................................................ទូរស័ព្ទរបស់អ្នកចុះតាមផ្ទះ៖.........................................

**មូលហេតុនៃការចុះតាមផ្ទះ** ( សូមជ្រើសរើសយកចំណុចខាងក្រោមតាមស្ថានភាពជាក់ស្តែង )

❑❑ សិស្សកំពុងខកខានមករៀន លើសពីបីថ្ងៃ

❑❑ សិស្សមានឥរិយាបថមិនល្អ ( ឧទាហរណ៍៖ គេចវេះសាលា, វាយតប់គ្នា, ... )

❑❑ សិស្សប្រឡងធ្លាក់១មុខវិជ្ជា ឬច្រើន

❑❑ ផ្សេងៗ សូមបញ្ជាក់៖..........................................................................................................

ឈ្មោះសិស្ស.........................ភេទ...........អាយុ.............ភូមិ...................ឃុំ/សង្កាត់................ថ្នាក់ទី.....ឈ្មោះសាលារៀន................................ឃុំ/សង្កាត់..............................ក្រុង/ស្រុក/ខណ្ឌ.......................................

មូលហេតុនៃការចុះតាមផ្ទះ ( សូមសរសេររៀបរាប់អំពីករណីរបស់សិស្សនោះ )

.......................................................................................................................................................

..........................................................................................................................

ពិពណ៌នាសកម្មភាពប្រជុំជាមួយមាតាបិតា ( រៀបរាប់សង្ខេបអំពីអ្វីដែលអ្នកបានពិភាក្សា )

.......................................................................................................................................................

..........................................................................................................................

ការសម្រេចចិត្តរវាងអ្នកចុះតាមផ្ទះ និងឪពុកម្តាយ/អ្នកអាណាព្យាបាលសម្រាប់សកម្មភាពបន្ត៖

.......................................................................................................................................................

..........................................................................................................................

កាលបរិច្ឆេទតាមដានបន្ត៖.................................អ្នកតាមដានបន្ត៖............................................

ហត្ថលេខា និងឈ្មោះអ្នកអាណាព្យាបាល និងលេខទូរស័ព្ទ

..........................................................................

ហត្ថលេខាអ្នកចុះតាមផ្ទះ

…………………………………………………………………………………

សកម្មភាពបន្ត ( រៀបរាប់សង្ខេប ដូចជា នរណា ? អ្វី ? កន្លែងណា ? នៅពេលណា ? ) ...................................................

.......................................................................................................

# ៥.២ តារាងកំណត់អត្តសញ្ញាណសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា ( គំរូ )

សិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា

ឈ្មោះសាលា ____________ ឈ្មោះគ្រូ______________ថ្នាក់ទី ______ កាលបរិច្ឆេទ __________

| ល.រ | នាម និង គោត្តនាម | ភេទ | អវត្តមាន ១០ ថ្ងៃឡើងទៅ/ ខែក្នុងឆមាសនេះ ឬ ឆមាសមុន | អាយុជាង ២ ឆ្នាំលើសកម្រិតថ្នាក់ | រស់នៅជាង១០ គីឡូម៉ែត្រ ពីសាលា | ធ្លាក់ភាសាខ្មែរ និង/ឬ ធ្លាក់២ ឬក៏ច្រើនជាង កាលពីឆមាសមុន | ធ្លាក់ភាសាខ្មែរ និង/ឬ ធ្លាក់២ ឬក៏ច្រើនជាង កាលពីខែមុន | ឥរិយាបថមិនល្អ ឬ ដាច់ឆ្ងាយពីសិស្សផ្សេងទៀត | កត្តាផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| * សិស្សទាំងអស់ដែលបំពេញតាមកត្តាហានិភ័យមួយ ឬច្រើនខាងលើ គួរត្រូវបានចាត់ដោយស្វ័យប្រវត្តិថាងាយប្រឈមនឹងការបោះបង់ការសិក្សា និងគួរបញ្ចូលឈ្មោះរបស់ពួកគេក្នុងតារាងនេះ។<br>* គួរធ្វើបច្ចុប្បន្នភាពតារាងនេះយ៉ាងហោចណាស់រាល់ខែ និងបន្ថែមឈ្មោះសិស្សផ្សេងទៀត។<br>* គ្រូបន្ទុកថ្នាក់គួររាយការណ៍ពីអន្តរាគមន៍នានាសម្រាប់សិស្សម្នាក់ៗក្នុងកិច្ចប្រជុំប្រចាំខែ។ | | | | | | | | | |
| ១ | ជា វាសនា | ប | បាទ/ចាស | | | ធ្លាក់ ៣ មុខវិជ្ជា | | | |
| 2 | អ៊ុក ពិសី | ស | | | | ធ្លាក់ភាសាខ្មែរ | | | |
| ៣ | រស់ ដារា | ប | | បាទ/ចាស | | | | បាទ/ចាស | |
| ៤ | សិតមុនីរ័ត្ន | ស | បាទ/ចាស | | | | | | ឪពុក/ម្ដាយឈឺធ្ងន់ |

# ៥.៣ ទម្រង់គ្រប់គ្រងករណី ( គំរូ )

ឈ្មោះសាលា______________ថ្នាក់ទី______ឈ្មោះគ្រូទទួលបន្ទុកថ្នាក់______________ប្រចាំខែ______ឆ្នាំ ២០______

| ល.រ | ឈ្មោះសិស្ស | លទ្ធផលសិក្សា | | | | | | | | សកម្មភាពគាំទ្រពីគ្រូ នាយក ឬសិស្ស | ជំហានបន្ទាប់/អនុសាសន៍/ ការទទួលខុសត្រូវ ផែនការ បន្ទាប់របស់គ្រូ និងនាយក |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ខែមុន | | | | ខែនេះ | | | | | |
| | | ខែ (ចំនួនមុខវិជ្ជាដែលធ្លាក់) | ខ្មែរ (ពិន្ទុ) | អវត្តមាន (ចំនួនថ្ងៃ) | ឥរិយាបថ (ល្អ, មធ្យម, អន់) | ខែ (ចំនួនមុខវិជ្ជាដែលធ្លាក់) | ខ្មែរ (ពិន្ទុ) | អវត្តមាន (ចំនួនថ្ងៃ) | ឥរិយាបថ (ល្អ, មធ្យម, អន់) | | |
| ១ | ជា វាសនា | ៣ | ៤០ | ១១ | ល្អ | ១ | ៤៥ | ២ | ល្អ | ការគាំទ្របន្ថែមផ្នែកភាសាខ្មែរដោយសិស្សច្បងនៅម៉ោងសម្រាក ការគាំទ្របន្ថែមពីគ្រូបន្ទុកថ្នាក់ | បន្ត និងលើកឡើងពីកម្មវិធីទូរស័ព្ទសម្រាប់ស្វ័យសិក្សា |
| ២ | អ៊ុក ពិសី | ១ | ៣០ | ០ | ល្អ | ១ | ៤០ | ០ | ល្អ | ការគាំទ្របន្ថែមផ្នែកភាសាខ្មែរដោយសិស្សច្បងនៅម៉ោងសម្រាក ការគាំទ្របន្ថែមពីគ្រូបន្ទុកថ្នាក់ | បន្ត និងលើកឡើងពីកម្មវិធីទូរស័ព្ទសម្រាប់ស្វ័យសិក្សា |
| ៣ | រស់ ដារា | ០ | ៥០ | ២ | អន់ | ០ | ៥៥ | ២ | មធ្យម | កិច្ចប្រជុំស្ដីពីការគ្រប់គ្រងករណីជាមួយសិស្ស និងមាតាបិតាដើម្បីឯកភាពលើឥរិយាបថល្អប្រសើរ ផ្លាស់ឱ្យអង្គុយជួរមុខ | បន្តតាមដាន និងកែតម្រូវឥរិយាបថ |
| ៤ | | | | | | | | | | | |
| ៥ | | | | | | | | | | | |

## ៥.៤ តារាងគ្រប់គ្រងឥរិយាបថ

| ឥរិយាបថ | វិធីសាស្ត្រគ្រប់គ្រង | ឥរិយាបថ | វិធីសាស្ត្រគ្រប់គ្រង |
|---|---|---|---|
| • មិនយកចិត្តទុកដាក់/ស្រមើស្រមៃ<br>• មិនធ្វើកិច្ចការសាលារៀន<br>• គ្មានសៀវភៅអាន<br>• មិនស្តាប់<br>• ងោក<br>• កាយវិការមិនគួរសម<br>• ទំពាស្ករគ្រាប់ ញ៉ាំនំក្នុងថ្នាក់ | • បង្កើត និងបិទប្រកាសបទបញ្ជាផ្ទៃក្នុងថ្នាក់រៀន/សាលារៀន និងឥរិយាបថសមរម្យ និងពិភាក្សាជាមួយសិស្ស<br>• រៀបចំសិស្សឱ្យសិស្សនោះអង្គុយជិតតុគ្រូ<br>• ដើរទៅជិតសិស្សនោះឈរក្បែរ ឬពីក្រោយតុសិស្ស<br>• ប្រើដៃជាសញ្ញា ( ដូចជាគោះតុ លើកដៃជាសញ្ញា។ល។ ដំឡើងសំឡេងបន្តិចធ្វើជាសញ្ញាប្រាប់សិស្សនោះកុំឱ្យប្រព្រឹត្តដូច្នោះទៀត<br>• កាន់ស្នាសិស្ស<br>• ហៅឈ្មោះសិស្សនោះ និងប្រាប់កុំឱ្យធ្វើ អាកប្បកិរិយាដូច្នេះទៀត<br>• បង្កើតនិតិវិធីច្បាស់លាស់សម្រាប់អនុវត្តជាប្រចាំ ( ឧទាហរណ៍លើកដៃបង្ហាញម្រាមបី រួចរាប់ ៣ ២ ១ ជាសញ្ញាឱ្យបញ្ឈប់ភ្លាម ) | • ជជែកជាមួយសិស្សដទៃ<br>• និយាយខ្លាំងៗពេលកំពុងធ្វើកិច្ចការ<br>• ចូលរៀនយឺត<br>• គប់ក្រដាសលេងក្នុងថ្នាក់<br>• វាយ បៀតបៀន គំរាមសិស្សដទៃ<br>• ប្រកែកតមាត់ជាមួយសិស្ស និងគ្រូ<br>• លេងសើចហៅឈ្មោះសិស្សដទៃ<br>• និយាយគំរោះគំរើយដាក់គ្រូ<br>• និយាយ ឬសម្តែងកាយវិការអាសអាភាស<br>• បំផ្លាញទ្រព្យសម្បត្តិសាលា<br>• និយាយតមាត់គ្រូ | • កោះប្រជុំជាមួយសិស្ស។ រួចប្រជុំជាមួយសិស្ស និងនាយក និងចុងបញ្ចប់ប្រជុំជាមួយគណៈកម្មការសាលារៀន និងឪពុកម្តាយ/អាណាព្យាបាល<br>• ចៀសវាងការដោះស្រាយជាមួយសិស្សនៅទីសាធារណៈ ត្រូវពិភាក្សាបញ្ហាឥរិយាបថផ្ទាល់ជាមួយសិស្ស<br>• កំណត់ការប្រព្រឹត្តមិនគប្បីរបស់សិស្ស និងរកដំណោះស្រាយ |

## ៥.៥ លិខិតអញ្ជើញអវត្តមាន ១០ ថ្ងៃ ( គំរូ )

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត...........

ឈ្មោះសាលា ....................................

# លិខិតអញ្ជើញ

**នាយក នាយិកា នៃ**...............................

**សូមគោរពអញ្ជើញ**

**ឪពុកម្តាយឬអាណាព្យាបាលសិស្សឈ្មោះ**................................................

**កម្មវត្ថុ:** អញ្ជើញចូលរួមប្រជុំពិភាក្សាពីករណីអវត្តមានរបស់កូនលោក លោកស្រី

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូនលោក លោកស្រីមេត្តាជ្រាបថា សិស្សឈ្មោះ............................. ភេទ............រៀនថ្នាក់ទី...............សាលា.......................អវត្តមាន ១០ ថ្ងៃក្នុងខែ..................ឆ្នាំ២០.... ដោយគ្មានមូលហេតុច្បាស់លាស់។ ការឈប់នេះអាចធ្វើឱ្យប៉ះពាល់ការសិក្សារបស់កូនហើយក៏អាចឱ្យ កូនមករៀនមិនទាន់គេ ឬបណ្តាលឱ្យប្រឡងធ្លាក់។ ការប្រជុំនេះមានគោលបំណង ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយជួយដល់កូនរបស់លោក លោកស្រីដែលបានឈប់ច្រើនដងនោះ ឱ្យកូនបានចូលរៀនជាប់លាប់ឡើងវិញ និងដើម្បីទប់ស្កាត់កុំឱ្យកូននេះបោះបង់ការសិក្សាទៀតផង។ គោលបំណងរបស់សាលារៀន គឺធានាឱ្យកូនរបស់អ្នកមានចំណេះដឹង ប៉ុន្តែសាលារៀនមិនអាចធ្វើតែម្នាក់ឯងបានឡើយ។ ដូច្នេះសាលារៀនត្រូវការពិភាក្សាជាមួយលោក លោកស្រីដើម្បីរិះរកវិធានការឱ្យកូនរបស់អ្នកមករៀនទៀងទាត់វិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមលោក លោកស្រីអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកុំបីខាននៅសាលា................ ..................................នៅថ្ងៃទី........ខែ............ឆ្នាំ២០.........វេលាម៉ោង...................ដើម្បីពិភាក្សាអំពីបញ្ហានេះរួមគ្នាកុំបីខាន។

សូមលោក លោកស្រីទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

ធ្វើនៅថ្ងៃទី......ខែ.......... ឆ្នាំ ២០....

នាយក

## ៥.៦ ទម្រង់កិច្ចសន្យាចូលរួម ( គំរូ )

បន្ទាប់ពីការពិភាក្សាអំពីសារៈសំខាន់នៃការសិក្សារបស់សិស្សរួចមករវាងសាលារៀន និងឪពុកម្ដាយ/អាណាព្យាបាល និងសិស្ស ជាផ្នែកមួយនៃប្រព័ន្ធរម្លឹកជាមុន ដើម្បីទប់ស្កាត់សិស្សបោះបង់ការសិក្សា ខ្ញុំបាទ/នាងខ្ញុំជាឪពុកម្ដាយ/អាណាព្យាបាល និងសិស្ស សូមប្ដេជ្ញាអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

១. សិស្ស៖

- អនុវត្តតាមវិន័យរបស់សាលារៀន និងគោរពម៉ោងសិក្សា
- ស្ដាប់ការណែនាំរបស់គ្រូ និងមតិល្អៗរបស់មិត្តភក្តិ
- ប្ដេជ្ញាធ្វើជាកូនល្អ សិស្សល្អ មិត្តល្អ
- ប្ដេជ្ញារៀនចប់អប់រំកម្រិតមូលដ្ឋាន
- មករៀនទៀងទាត់ និងទាន់ពេលវេលា

២. ឪពុកម្ដាយ/អាណាព្យាបាល៖

- លើកទឹកចិត្ត និងផ្ដល់ឱកាសឱ្យកូនរៀនបន្ថែមនៅផ្ទះ។
- មិនឱ្យកូនធ្វើការធ្ងន់ធ្ងរប៉ះពាល់ដល់ម៉ោងសិក្សា។
- គាំទ្រពេញទំហឹងការប្ដេជ្ញារបស់កូនរៀនចប់អប់រំកម្រិតមូលដ្ឋាន
- សហការជាមួយគ្រូទទួលបន្ទុកថ្នាក់ក្នុងការតាមដានការសិក្សារបស់កូន
- ចូលប្រជុំជាមួយសាលារៀនតាមការអញ្ជើញ

យើងខ្ញុំយល់ព្រមអនុវត្តខ្ជាប់ខ្ជួនវិន័យទាំងនេះ និងរួមចំណែកកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់កម្មវិធីទប់ស្កាត់សិស្សបោះបង់ការសិក្សា និងឆ្លៀតយកឱកាសនេះប្រែក្លាយខ្លួនទៅជាពលរដ្ឋដ៏ល្អម្នាក់ក្នុងពេលអនាគត។

ដើម្បីជាភស្តុតាង យើងខ្ញុំសូមចុះហត្ថលេខា ឬស្នាមមេដៃ ដូចខាងក្រោម៖

| | |
|---|---|
| ______________________ | ______________________ |
| ឈ្មោះ និងហត្ថលេខារបស់សិស្ស | កាលបរិច្ឆេទ |
| ______________________ | ______________________ |
| ហត្ថលេខាឪពុកម្ដាយ/អាណាព្យាបាល | កាលបរិច្ឆេទ |

ហត្ថលេខាគ្រូបន្ទុកថ្នាក់ | កាលបរិច្ឆេទ

ហត្ថលេខានាយកសាលា | កាលបរិច្ឆេទ

**សេចក្តីណែនាំ៖**

នៅចុងបញ្ចប់នៃការជួបពិភាក្សាជាមួយឪពុកម្តាយ/អាណាព្យាបាល នៅទីចាត់ការសាលា ស្តីពីអំពីសិស្សអវត្តមាន ១០ថ្ងៃ ឪពុកម្តាយ/អាណាព្យាបាល និងកូនរបស់គាត់ត្រូវបានស្នើចុះហត្ថលេខាលើទម្រង់ "កិច្ចសន្យាចូលរួម" នេះបង្ហាញពីការប្តេជ្ញាចិត្តបន្តការសិក្សា និងគាំទ្រការសិក្សារបស់កូន។ សូមកត់សម្គាល់ថា៖ ការប្រជុំនេះធ្វើនៅទីចាត់ការសាលា អនុវិទ្យាល័យ ប៉ុន្តែក្នុងករណីឪពុកម្តាយ/អាណាព្យាបាល មិនអាចមកសាលារៀនតាមការអញ្ជើញ និងមានការយល់ព្រមឱ្យជួបនៅផ្ទះ នោះនាយក/នាយករង និងគ្រូទទួលបន្ទុកថ្នាក់អាចចុះដល់ផ្ទះផ្ទាល់។

## ៥.៧ ធនធានបន្ថែមសម្រាប់ជួយដល់ស្វ័យសិក្សា

មានអង្គការជាច្រើនដែលបានផលិតឯកសារអំណាន និងកម្មវិធីតាមបណ្តាញអ៊ីនធើណិតដើម្បីជួយដល់ការសិក្សារបស់សិស្ស ដែលជាញឹកញាប់អាចដោនឡូតបានដោយមិនគិតថ្លៃ ឬមានឱ្យប្រើប្រាស់ក្នុងតម្លៃទាប។

**ឯកសារអំណានសំខាន់ៗ និងអំណានសម្រាប់ថ្នាក់ដំបូង**

- ទំព័រហ្វេសប៊ុក **All Children Reading – Cambodia** ជាប្រភពធនធានដ៏ល្អសម្រាប់ឯកសារអំណានបន្ថែមដែលឯកសារខ្លះអាចចូលមើលដោយមិនគិតថ្លៃ និងអាចដោនឡូតបាន ៖ www.facebook.com/allchildrenreadingcambodia។
- **ធនធានអំណានថ្នាក់ដំបូង** bit.ly/KhmerLiteracy ( ផ្អែកតាមករណី ) ឬ http://cambodia.worlded.org/our-projects/resources/ មានតារាងឯកសារឌីជីថលសម្រាប់ការសិក្សាថ្នាក់ដំបូង និងការបង្រៀនពីដៃគូអប់រំជាច្រើន និងត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ។
- **កម្មវិធី The Aan Khmer-អានខ្មែរ** អាចចូលមើលដោយមិនគិតថ្លៃក្នុង Google Playstore និងអាចដោនឡូតបានដោយមិនគិតថ្លៃ និងជួយឱ្យសិស្សរៀនអនុវត្តអំណាន និងផ្អែកតាមសៀវភៅសិក្សាថ្នាក់ទី ១ និងទី ២ របស់ក្រសួងអប់រំ យុវជន និងកីឡា។
- **កម្មវិធី សៀវភៅឆ្លាត ក្នុង Playstore ៖** https://play.google.com/store/apps/details?id=org.kape.smartbooks មានគោលដៅបង្កើនសមត្ថភាពអំណានថ្នាក់ទី២ និងទី៣ របស់សិស្ស ដែលអាចចូលដោនឡូតដោយមិនគិតថ្លៃ។ ទម្រង់ពេញលេញនៃកម្មវិធីសៀវភៅឆ្លាតអាចដោនឡូតតាមតំណភ្ជាប់នេះ ៖ https://drive.google.com/open?id=1zqTl2DWaXx2CMXRAagZjJIAsdQFqFxy
- **តោះយើងអាន! Let's Read! បណ្ណាល័យឌីជីថលសម្រាប់សិស្ស** មានក្នុង Playstore ៖ https://play.google.com/store/apps/details?id=org.asiafoundation.letsread

- **រឿងអប់រំ** គឺជាកម្មវិធីអំណានដែលផលិតឡើងដោយគម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន (Tiger) និងមានរឿងអប់រំ ជាច្រើនសម្រាប់ឱ្យសិស្សអាន ៖ https://play.google.com/store/apps/details?id=com.tigermobile
- **កម្មវិធីតេស្តអំណាន (TestApp)** គឺជាឧបករណ៍វិភាគដំណើរការសិក្សាដែលប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ថ្នាក់ដំបូង។ មានកម្មវិធីមួយសម្រាប់សិស្ស (តេស្តអំណានសម្រាប់សិស្ស) ៖ https://play.google.com/store/apps/details?id=com.cammob.test_app.student និងកម្មវិធីមួយសម្រាប់គ្រូ (តេស្តអំណានសម្រាប់គ្រូ) ៖ https://play.google.com/store/apps/details?id=com.cammob.test_app.teacher

**ធនធានសំណេរថ្នាក់ដំបូង**

- **សរសេរខ្មែរ (Sorse Khmer)** គឺជាកម្មវិធីសម្រាប់ឱ្យសិស្សថ្នាក់ទី ១ រៀនសរសេរ ៖ https://play.google.com/store/apps/details?id=org.kape.khmerwriting

**ធនធានប្រឹក្សាអាជីព**

- **ត្រីវិស័យ (Trey Visay)** គឺជាកម្មវិធីប្រឹក្សាអាជីពតាមអ៊ីនធើណេត ៖ https://play.google.com/store/apps/details?id=com.treyvisay

**សម្ភារឧបទ្ទេសដែលមានតម្លៃទាប ៖** ប្រសិនបើសាលារៀន ម្ចាស់ជំនួយ ឬមាតាបិតាចង់បានសម្ភារឧបទ្ទេសមានតម្លៃទាបសម្រាប់សិស្ស មានឯកសារជាច្រើនសម្រាប់មុខវិជ្ជាទាំងបួននៅបឋមសិក្សាដែលស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ៖ www.tts-kape.org ឬ www.facebook.com/ttskape/

# ៥.៨ ករណីសិក្សាស្តីពីសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា

ករណីសិក្សា និងរឿងរ៉ាវដូចខាងក្រោមមានសារប្រយោជន៍សម្រាប់ការហ្វឹកហ្វឺនដល់បុគ្គលិកដែលអនុវត្តក្នុងការដោះស្រាយបញ្ហា ដែលពួកគាត់អាចជួបប្រទះពេលសិស្សរបស់គាត់អវត្តមាន។ ករណីសិក្សាអាចសមស្របសម្រាប់ប្រើជាមួយក្រុមប្រឹក្សាកុមារ និងសហគមន៍ ហើយអាចប្តូរទៅជាការសម្តែងតួ ដើម្បីសម្តែងនៅក្នុងពិធីទិវាជាតិ។

## ៥.៨.១ សិស្សធុញទ្រាន់នឹងការរៀន ប៉ុន្តែឪពុកម្តាយជំរុញឱ្យរៀន

តារា ជាកូនពៅរបស់អាជីវករ ដែលឪពុកម្តាយជាអ្នកលក់ដូរនៅក្បែរផ្សារមួយ។ ជាធម្មតាអាណាព្យាបាលតែងតែមានចម្ងល់ស្ទើរគ្រប់ម៉ោងសិក្សាចំពោះកូនគាត់។

ឪពុក: ហេតុអ្វីបានជាកូនធុនទ្រាន់និងការរៀន?

តារា:បាទពុក បានជាកូនធុញទ្រាន់និងការទៅសាលារៀនជាប្រចាំពីព្រោះមានបញ្ហា៖

- មានមិត្តភក្តិមួយចំនួនតូចបានធ្វើបាបជំរិតទារប្រាក់
- សាលារៀនមានលក្ខណៈមិនស្អាត និងកខ្វក់ខ្លាំង
- ខ្វះការលើកទឹកចិត្តពីគ្រូបង្រៀន
- ខ្ញុំមានអាយុច្រើនជាងគេក្នុងថ្នាក់រៀន
- ហើយខ្ញុំក៏មានបញ្ហាសុខភាពដែរពុក

ឪពុកៈ ពុកយល់ពីបញ្ហារបស់កូនហើយ ដូចនេះពុកមានដំណោះស្រាយឱ្យកូនបានទៅរៀនទៀងទាត់ឡើងវិញ។ ពុកនឹងរាយការណ៍ទៅនាយកសាលារៀនឱ្យចាត់វិធានការលើមិត្តភក្តិដែលបានជំរិតទារប្រាក់ សុំឱ្យគាត់ចាត់ចែងសិស្សយាមការពារសាលារៀន និងបន្ទប់រៀនស្អាត ហើយផ្តល់ដំណឹងដល់គាត់ឱ្យប្រាប់គ្រូលើកទឹកចិត្តដល់កូន។ ចំពោះបញ្ហាលើសអាយុសិក្សា កូនកុំបារម្ភការសិក្សាមានសារៈសំខាន់ក្នុងវ័យកូននេះ សំខាន់គឺពុកត្រូវថែរក្សាសុខភាពកូនឱ្យបានល្អដោយធានាថាកូនហូបអាហារស្អាត និងមានជីវជាតិគ្រប់គ្រាន់ ដើម្បីរៀនបានពូកែ។

ចាប់ពីពេលនោះមក តារាទៅរៀនយ៉ាងទៀងទាត់ជាមួយភាពក្លាហាន និងទទួលបានលទ្ធផលសិក្សាល្អ។

សំណួរត្រិះរិះពិចារណា

១ ហេតុអ្វីបានជាតារា ធុញទ្រាន់នឹងការរៀន?

- មានការគំរាមកំហែងពីមិត្តភក្តិ
- សាលារៀនមានលក្ខណៈមិនទាក់ទាញ (កុមារមេត្រី)
- ខ្វះការលើកទឹកចិត្តពីគ្រូបង្រៀន
- លើសអាយុ ចូលរៀន
- មានបញ្ហាសុខភាព

២ តើឪពុករបស់តារាដោះស្រាយបញ្ហាយ៉ាងដូម្តេច?

- ផ្តល់បញ្ហារបស់តារាឱ្យនាយកបានដឹងដូចជា មានការគំរាមកំហែងពីមិត្តភក្តិ កែលម្អសាលារៀនទៅជាសាលាកុមារមេត្រី គ្រូបង្រៀនត្រូវមានការលើកទឹកចិត្តដល់សិស្ស
- ស្នើសុំឱ្យនាយកកែលម្អសាលារៀនដោយធានាថាវាត្រូវបានសម្អាតជាប្រចាំ
- រម្លឹកនាយកសាលាឱ្យស្នើសុំឱ្យគ្រូលើកទឹកចិត្តដល់សិស្សរបស់គាត់
- ការសិក្សាមិនបានគិតពីអាយុលើស
- ចំពោះបញ្ហាសុខភាពគឺឪពុកម្តាយជាអ្នកមើលថៃ និងធានាថាកូនហូបអាហារស្អាត និងមានជីវជាតិគ្រប់គ្រាន់

## ៥.៨.២ មូលហេតុដែលសិស្សរៀនពូកែហើយបោះបង់ការសិក្សា

### រឿងខ្លី

សុភាពជាសិស្សដែលរៀនពូកែនៅថ្នាក់ទី៨ នៃអនុវិទ្យាល័យមួយ។ សុភាពមានបងប្អូន៦នាក់រួមទាំងរូបនាង ឪពុករបស់នាងធ្វើការងារសំណង់ ហើយម្តាយរបស់នាងជាមេផ្ទះ មើលកូន មើលគោ និងធ្វើស្រែចំការ។

នៅចុងឆមាសទី២ ការសិក្សារបស់សុភាពធ្លាក់ចុះ ដោយមករៀនមិនទាន់ពេលវេលា និងមានអវត្តមានលើសពី៣ដងក្នុងមួយខែ។ គ្រូបន្ទុកថ្នាក់ក៏បានហៅសុភាពមកសួរនាំអំពីបញ្ហានេះ។

គ្រូបន្ទុកថ្នាក់បានយកបញ្ហារបស់សុភាពទៅពិភាក្សាជាមួយនាយកសាលា ដើម្បីរកវិធីដោះស្រាយ បញ្ហាទាំងអស់នោះគឺ៖

- គ្រួសារខ្ញុំមានជីវភាពក្រីក្រ
- សុភាពចង់ឈប់រៀនដើម្បីទៅធ្វើការនៅរោងចក្រ ហើយឱ្យឪពុកនាងមកធ្វើស្រែចំការវិញ។

- បញ្ហាសុវត្ថិភាពក្នុងការធ្វើដំណើរមកសាលារៀន
- ខ្វះមធ្យោបាយធ្វើដំណើរ និងសម្ភារសិក្សា

ក្រោយពីបានពិភាក្សាជាមួយនាយករួច គ្រូបន្ទុកថ្នាក់បានចុះទៅតាមដានដល់ផ្ទះរបស់នាង ប៉ុន្តែត្រូវបានឪពុកម្ដាយនាងស្ដីបន្ទោស និងបដិសេធ។

ដោយមានការអាណិត និងស្ដាយការសិក្សារបស់សុភាព គ្រូបន្ទុកបានទាក់ទងតាមទូរសព្ទទៅឪពុកម្ដាយសុភាពម្ដងទៀត ប៉ុន្តែត្រូវបានឪពុកម្ដាយនាងស្ដីបន្ទោស និងបដិសេធដដែល។

បន្ទាប់មកនាយកសាលាបានធ្វើលិខិតអញ្ជើញឪពុកម្ដាយនាងមកប្រជុំនៅសាលាជាមួយអាណាព្យាបាលសិស្សដែលប្រឈមដទៃទៀតប៉ុន្តែលទ្ធផលសិក្សារបស់សុភាពនៅដដែល។

ដោយមានការព្យាយាម គ្រូបន្ទុកថ្នាក់បានអញ្ជើញ នាយកសាលា និងតំណាងសហគមន៍ចុះទៅជួបឪពុកម្ដាយសុភាពដើម្បីពិភាក្សាម្ដងទៀត។ ដើម្បីធានាការសិក្សារបស់សុភាព តំណាងសហគមន៍បានធានាជួយធ្វើស្រែចំការ និងស្វែងរកសប្បុរសជនដើម្បីដោះស្រាយមធ្យោបាយធ្វើដំណើរ។

លោកនាយកសាលាបានធានាជួយសម្ភារសិក្សា នាំសិស្សជួយច្រូតកាត់ និងរៀបចំក្រុមបណ្ដាញភូមិ។ គ្រូបន្ទុកថ្នាក់ក៏បានធានាជួយជំរុញការសិក្សារបស់សុភាពឱ្យទទួលបានជោគជ័យឪពុកម្ដាយសុភាពក៏បានសន្យាជំរុញសុភាពឱ្យបន្តការសិក្សាដូចដើមវិញ។ ទីបញ្ចប់សុភាពបានទៅរៀនសូត្រជាប់លាប់និងបានទទួលលទ្ធផលល្អ។

**បញ្ហា៖**

- គ្រួសារមានភាពក្រីក្រ
- មានកូនច្រើន
- ឱកាសការងារ
- បរិយាកាសសង្គម

**គំនិតពិចារណា**

- តើយើងគួរជួយជំរុញការសិក្សារបស់កូន ឬយល់ព្រមតាមអាណាព្យាបាល ?

**ដំណោះស្រាយ**

- គ្រូបន្ទុកថ្នាក់ជួបសំណេះសំណាលផ្ទាល់ជាមួយសិស្សនោះ
- គ្រូបន្ទុកថ្នាក់ពិភាក្សាជាមួយនាយកសាលាដើម្បីជួយសិស្សនោះ
- គ្រូបន្ទុកថ្នាក់អនុវត្តតាមទម្រង់ករណី

### ៥.៨.៣ សិស្សរៀនពូកែឪពុកម្ដាយមានលទ្ធភាពតែមិត្តភក្តិអូសទាញឱ្យចំណាកស្រុក

ចរិយាជាកុមារីរៀនថ្នាក់ទី៨ ជាសិស្សពូកែក្នុងថ្នាក់ម្នាក់តែងតែទទួលបានលទ្ធផលការសិក្សាល្អ ហើយលោកគ្រូអ្នកគ្រូ និងមិត្តភក្តិបានលើកសរសើរ។ ឪពុកម្ដាយតែងតែលើកទឹកចិត្តចរិយាឱ្យខិតខំរៀនសូត្រព្រមទាំងផ្គត់ផ្គង់សម្ភារគ្រប់បែបយ៉ាងដល់ការសិក្សារបស់ចរិយា។

ថ្ងៃមួយចរិយាបានទៅចូលរួមកម្មវិធីបុណ្យនៅផ្ទះមិត្តភក្តិដែលបានឈប់រៀនយូរមកហើយ។ នាងបានទិញសម្ភារទំនើបៗសម្រាប់ប្រើប្រាស់ក្នុងផ្ទះដោយសារនាងបានទៅធ្វើការនៅឯក្រៅប្រទេស។

ចរិយាសួរនាងថា ឯងទៅប្រទេសគេធ្វើអ្វី ហើយបានប្រាក់ខែប៉ុន្មាន ?

នាងឆ្លើយថា ខ្ញុំបានធ្វើការផ្នែកថែទាំកុមារ និងបានប្រាក់ខែខ្ពស់ ទោះបីអ្នកមិនចេះអក្សរឬគ្មានជំនាញក៏មិនខ្វះការងារធ្វើដែរ។

ចរិយាមានចិត្តរាំរែកក្រោយពីស្តាប់មិត្តភក្តិធ្វើឱ្យការសិក្សារបស់ខ្លួនថយចុះជាលំដាប់។

ឪពុកម្តាយក្រោយពីបានឃើញសៀវភៅតាមដានការសិក្សារបស់កូនត្រូវបានគ្រូបន្ទុកថ្នាក់ចុះមូលវិចារណ៍ថា ចរិយាឈប់ប្រាំដងហើយទទួលលទ្ធផលការសិក្សាមិនល្អ ក៏ហៅចរិយាមកសួរ៖

ហេតុអ្វីបានជាកូនអវត្តមានច្រើនក្នុងខែនេះ ហើយការសិក្សារបស់កូនថយចុះថែមទៀត?

ចរិយាឆ្លើយថាៈ កូនចង់ទៅធ្វើការជាមួយមិត្តភក្តិក្រៅប្រទេស ព្រោះគេមិនចេះអក្សរក៏អាចមានការងារធ្វើ និងទទួលបានប្រាក់ខែខ្ពស់ទៀតផង។ ដូចនេះខ្ញុំចង់សុំពុកម៉ែឈប់រៀនទៅធ្វើការជាមួយមិត្តភក្តិ។

**សំណួរត្រិះរិះ**

១.តើឪពុកម្តាយចរិយាមានវិធីសាស្ត្រណា ដើម្បីទប់ស្កាត់កូនកុំឱ្យឈប់រៀន?

២.សាលារៀន សហគមន៍ ត្រូវមានវិធីណាខ្លះដើម្បីឱ្យចរិយានៅបន្តការសិក្សា?

៣.គ្រូបង្រៀនត្រូវពន្យល់យ៉ាងណាដើម្បីឱ្យចរិយាយល់អំពីតម្លៃការសិក្សា?

៤.តើចរិយាប្តូរឥរិយាបថយ៉ាងណាក្រោយពីទទួលបានការណែនាំ?

**ដំណោះស្រាយ**

១.ពុកម៉ែត្រូវពន្យល់ហេតុផលដល់កូន៖ ពុកម៉ែមានលទ្ធភាពផ្គត់ផ្គង់ការសិក្សារបស់កូនរហូតដល់ទីបញ្ចប់ និងរកថវិកាទិញសម្ភារៈទំនើបឱ្យនៅពេលកូនរៀនចប់ទទួលបានលទ្ធផលល្អ។

២.កូនត្រូវដឹងថាការធ្វើការដោយកម្លាំងវាទទួលបានផលនៅពេលមានកម្លាំងធ្វើតែប៉ុណ្ណោះ រីឯវិជ្ជាវិញកូនយកទៅប្រើដោយមិនចាំបាច់ប្រើកម្លាំង មានការងារល្អធ្វើ ទទួលបានប្រាក់ខែច្រើន សេចក្តីសុខពេញមួយជីវិត។

៣.សាលារៀន និងសហគមន៍ត្រូវចុះដល់ផ្ទះ ចរិយា ព្រមទាំងលើកទឹកចិត្តឱ្យគាត់ខិតខំរៀនសូត្របន្ត និងពន្យល់ឱ្យគាត់យល់តម្លៃនៃការសិក្សា។

៤.គ្រូបង្រៀនសុំណាត់ជួប ចរិយា និងពន្យល់ពីសារប្រយោជន៍នៃការសិក្សា ជាពិសេសសិស្សរៀនពូកែនឹងទទួលបានអាហារូបករណ៍។

៥.ក្រោយពីបានទទួលការពន្យល់គ្រប់ពីអ្នកពាក់ព័ន្ធរួចមក ចរិយាបានប្តូរចិត្តបន្តការសិក្សាតទៅទៀត ហើយបានសន្យាថាខិតខំរៀនឱ្យក្លាយជាសិស្សពូកែ។

### ៥.៨.៤ សិស្សគេចសាលាមិនចូលរៀនទៅលេងល្បែងនៅជុំវិញសាលា

សាលារៀនមួយស្ថិតនៅក្នុងទីប្រជុំជនមិនឆ្ងាយប៉ុន្មានពីទីក្រុងភ្នំពេញ។ គេឃើញមានសិស្សានុសិស្សមករៀនយ៉ាងកុះករ។ ប៉ុន្តែនៅពេលសាលាបានធ្វើការបូកសរុបអវត្តមាននិងពិន្ទុប្រចាំខែ បានបង្ហាញថា សិស្សមួយចំនួនតូចមានអវត្តមានច្រើនគួរកត់សម្គាល់។ លោកគ្រូ អ្នកគ្រូទទួលបន្ទុកថ្នាក់បានស្រង់ពិន្ទុនិងអវត្តមានដាក់ក្នុងសៀវភៅតាមដានការសិក្សាហើយបានបញ្ជូនទៅឱ្យអាណាព្យាបាលសិស្សរៀងៗខ្លួន តាមរយៈអាជ្ញាធរដែនដី សហគមន៍ មិត្តភក្តិ និងសាមីខ្លួន។

តាមការផ្តល់ព័ត៌មានរបស់នាយកសាលាថា មានសិស្សម្នាក់ ឈ្មោះ ឡុង ដា ដែលមានអវត្តមានច្រើន។

ក្រោយពេលឪពុក ឡុង ដា ឈ្មោះ សំ បានទទួលសៀវភៅតាមដានការសិក្សារបស់កូន។ គាត់មានចិត្តខឹងសម្បារនឹងកូនហើយបានហៅកូនមកសួរថា ពុកឃើញកូនមកសាលា រៀងរាល់ថ្ងៃ ចុះហេតុអីបានជាកូនមានអវត្តមានច្រើនម្ល៉េះ ?

ដា: ខ្ញុំមកចូលរៀនដែរ តែពេលខ្លះ លោកគ្រូគាត់មិនមក

សំ: មែនឬ! ពុកមិនទាន់ជឿសម្តីកូនទាំងស្រុងទេ តែពេលនោះកូនទៅណា ?

ដា: ខ្ញុំបានទៅដើរលេងជាមួយមិត្ត

សំ: តើកូនដើរលេងនៅទីណា? កូនត្រូវដឹងថា មិត្តល្អនាំកូនខិតខំសិក្សា ឯមិត្តខ្លះមិនល្អនាំ កូនដើរលេងល្បែងផ្សេងៗ ដែលនាំឱ្យកូនពុំមានអនាគតល្អ

ដា: ខ្ញុំមិនបានដើរលេងឆ្ងាយទេ គឺនៅជិតៗសាលាដែលមានល្បែងច្រើនប្រភេទ។

សំ: ឥឡូវកូនគិតថា ការសិក្សានិងការដើរលេងល្បែងមួយណាប្រសើរជាងសម្រាប់កសាងជីវភាពគ្រួសារទៅថ្ងៃអនាគត

ដា: ការសិក្សាល្អជាង លោកពុក

សំ: បើកូនយល់ដូច្នេះ តើកូនត្រូវសម្រេចចិត្តធ្វើដូចម្តេចខ្លះ ?

ដា: ខ្ញុំសម្រេចចិត្តថា ត្រូវខិតខំរៀនសូត្រ មករៀនបានទៀងទាត់ពេល ឈប់ដើរលេងល្បែង និងមិនសេពគប់ជាមួយមិត្តភក្តិដែលដើរលេងច្រើន

សំ: ប្រសើរណាស់កូន ពុកសង្ឃឹមថា កូននឹងមិនឱ្យឪពុកនិងក្រុមគ្រួសារពិបាកចិត្តទៀតទេ។

មួយសប្តាហ៍ក្រោយមក ពូសំបានទទួលលិខិតអញ្ជើញមួយច្បាប់ពីលោកនាយកសាលា។ គាត់ក៏បានទៅជួបលោកនាយកនិងលោកគ្រូ អ្នកគ្រូតាមពេលកំណត់។ លោកនាយកបានជម្រាបជូន ពូសំអំពីលទ្ធផលសិក្សានិងអវត្តមានរបស់ឡុង ដាថា ខ្ញុំបានណែ នាំដា ជាច្រើនដង ថែមទាំង ដាបានធ្វើកិច្ចសន្យាជាមួយខ្ញុំទៀត តែដានៅតែឈប់ច្រើន។ ឮដូច្នេះ ពូសំក៏បានថ្លែងអំណរគុណដល់លោកនាយកនិងលោកគ្រូអ្នកគ្រូដែលបានយកចិត្តទុកដាក់ណែនាំកូនរបស់គាត់។ ពូសំក៏បានជម្រាបជូននាយកថា ខ្ញុំបានណែនាំនិងសាកសួរកូនអំពីបញ្ហានេះដែរ។កូនខ្ញុំប្រាប់ថា មានល្បែងនៅជុំវិញសាលានិងលោកគ្រូខ្លះមិនមកបង្រៀនតាមម៉ោងសិក្សាជាមូលហេតុធ្វើឱ្យខ្ញុំឈប់ច្រើន។ តាមសម្តីកូន ខ្ញុំជាឪពុកក៏មិនទាន់ជឿទាំងស្រុងទេ។ ចុងបញ្ចប់លោកនាយកបានតាំងចិត្តថា ក្នុងករណីនេះខ្ញុំនឹងធ្វើការតាមដានបន្តទៀតនិងរកដោះស្រាយ។

**សំណួរត្រិះរិះ**

១. តើជុំវិញសាលារៀន គួរមានល្បែងបន្តទៀតដែរឬទេ ?

២. តើករណី ឡុង ដា បានគេចសាលាដោយសារ ល្បែងនៅជុំវិញសាលាឬដោយសារគណៈគ្រប់គ្រងសាលា ?

៣. តើមានវិធានការអ្វីខ្លះដើម្បីដោះស្រាយចំពោះបញ្ហានេះ ?

**ដំណោះស្រាយ**

១. គណៈគ្រប់គ្រងសាលាត្រូវបង្កើនការងារអធិការកិច្ចលើការងារបង្រៀននិងរៀនរបស់គ្រូនិងសិស្ស។

២. គ្រូគ្រប់មុខវិជ្ជាត្រូវពិនិត្យវត្តមានសិស្សរាល់ម៉ោងសិក្សា។

៣. គ្រូទទួលបន្ទុកថ្នាក់ត្រូវធ្វើការបូកសរុបអវត្តមានសិស្សជាប្រចាំដើម្បីរាយការណ៍ជូនគណៈគ្រប់គ្រងសាលា និងអាណាព្យាបាលសិស្សករណីសិស្សអវត្តមានច្រើនដង។

៤. មាតាបិតាសិស្សត្រូវចូលរួមតាមដានការសិក្សារបស់កូនតាមរយៈសៀវភៅតាមដានការសិក្សានិងតាមការអញ្ជើញរបស់សាលា។

៥. នាយកសាលាត្រូវសហការនិងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរដែនដីអំពីទីតាំងល្បែងនានានៅជុំវិញសាលាឬកន្លែងផ្សេងៗ។

Supported by:

unicef
for every child